ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងទេសចរណ៍

# ផែនការយុទ្ធសាស្ត្រ
# អភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យទេសចរណ៍
# ២០១៧ - ២០២៥

# *STRATEGIC PLAN FOR TOURISM HUMAN RESOURCES DEVELOPMENT*
# *2017 – 2025*

2017



**មតិស្វាគមន៍**

**ឯកឧត្តមបណ្ឌិត ថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍**

**និងជាប្រធានគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍**

**ស្ថាប័នបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ ប្រតិបត្តិករទេសចរណ៍**
**និងអ្នកជំនាញទេសចរណ៍ ជាទីរាប់អាន!**

តាងនាមឱ្យក្រសួងទេសចរណ៍ គណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍ និងរូបខ្ញុំផ្ទាល់ ខ្ញុំមានកិត្តិយស និងសេចក្តីសប្បាយរីករាយជម្រាបជូនស្ថាប័នបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ ប្រតិបត្តិករទេសចរណ៍ និងអ្នកជំនាញទេសចរណ៍ ជ្រាបថា ក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងឈ្លាសវៃប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បច្ចុប្បន្ន កម្ពុជាមានសុខសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខសណ្តាប់ធ្នាប់ពេញលេញ និងមានការអភិវឌ្ឍរីកចំរើនលើគ្រប់វិស័យ ក្នុងនោះ វិស័យទេសចរណ៍ក៏មានការរីកចម្រើនគួរឱ្យកត់សម្គាល់ផងដែរ។

វិស័យទេសចរណ៍ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាចាត់ទុកជា**មាសបៃតង** និង**ជាការនាំចេញនៅនឹងកន្លែង** ចូលរួមអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម តាមរយៈការបង្កើតប្រាក់ចំណូលជូនជាតិ បង្កើតការងារ ជំរុញការវិនិយោគ និងចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋបានយ៉ាងប្រសិទ្ធភាព។ ការផ្សព្វផ្សាយទេសចរណ៍កម្ពុជា **"កម្ពុជា៖ ព្រះរាជាណាចក្រអច្ឆរិយៈ ផ្តល់ភាពកក់ក្តៅ - Cambodia: Kingdom of Wonder Feel the Warmth"** បានជំរុញកំណើនទេសចរជាតិ និងអន្តរជាតិមកកម្ពុជាគួរឱ្យកត់សម្គាល់។ ដើម្បីបន្តជំរុញ និងរក្សានូវនិរន្តរភាពនៃកំណើននេះ ក្រសួងទេសចរណ៍បានអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍កម្ពុជា រយៈពេលខ្លី វែង និងមធ្យម ដោយផ្តោតសំខាន់លើការអភិវឌ្ឍផលិតផលថ្មី ការផ្សព្វផ្សាយ ការពង្រឹង គុណភាពសេវាកម្ម ការអភិវឌ្ឍធនធានមនុស្ស និងហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់ផ្សេងៗទៀត ស្របតាមនិន្នាការទេសចរណ៍ សកលលោក និងតំបន់។

ទន្ទឹមនឹងនេះផងដែរ ដើម្បីធានាបាននូវការអភិវឌ្ឍទេសចរណ៍កម្ពុជាប្រកបដោយនិរន្តរភាព ការទទួលខុសត្រូវ និងបរិយាប័ន្ន ក្រសួងទេសចរណ៍បានចាត់ទុកការអភិវឌ្ឍមូលធនមនុស្ស ជាកត្តាគន្លឹះ ពោលគឺបានយកចិត្តទុកដាក់ខ្ពស់លើការពង្រឹងការអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ ដោយផ្តល់នូវជំនាញច្បាស់លាស់ដល់អ្នកជំនាញទេសចរណ៍ រួមមាន សិស្ស-និស្សិត និងអ្នកកំពុងបម្រើការងារ ស្របតាមយន្តការជាតិ និងអាស៊ាន។ ក្នុងន័យនេះ ក្រសួងទេសចរណ៍ ដែលមានគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍ជាសេនាធិការ បានដាក់ចុះអនុវត្តកម្មវិធីសិក្សាជំនាញទេសចរណ៍ស្តង់ដារអាស៊ាន នៅតាមសាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍នានានៅកម្ពុជា សំដៅធ្វើឲ្យសិស្ស-និស្សិត ដែលបញ្ចប់ការសិក្សាទទួលបានវិញ្ញាបនបត្រ ឬសញ្ញាបត្រវិជ្ជាជីវៈទេសចរណ៍ទទួលស្គាល់ដោយអាស៊ាន និងមានលទ្ធភាពចាប់យកឱកាសការងារក្នុងតំបន់ស្របតាមស្មារតីនៃកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកលើអ្នកជំនាញទេសចរណ៍ អាស៊ាន (ASEAN MRA - TP)។

ក្នុងន័យនេះ ដើម្បីជំរុញការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យទេសចរណ៍ប្រកបដោយប្រសិទ្ធភាព និងគ្រប់ជ្រុងជ្រោយ ក្រសួងទេសចរណ៍ និងគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍បានដាក់ចេញ "**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យទេសចរណ៍ ២០១៧-២០២៥**" ដែលត្រូវបានរៀបចំឡើងស្របតាមគោលនយោបាយជាតិបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ២០១៧-២០២៥ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍទេសចរណ៍អាស៊ាន ២០១៦-២០២៥ សំដៅលើកកម្ពស់គុណតម្លៃជំនាញវិជ្ជាជីវៈទេសចរណ៍ បណ្តុះបណ្តាល និងពង្រឹងសមត្ថភាពស្ថាប័ន មន្ត្រីជំនាញ និងអ្នកជំនាញទេសចរណ៍ស្របតាមស្តង់ដាអាស៊ាន និងវិថីការងារច្បាស់លាស់។ ផែនការយុទ្ធសាស្ត្រមានចក្ខុវិស័យ "**នៅឆ្នាំ២០២៥ កម្ពុជានឹងមានអ្នកជំនាញទេសចរណ៍ ដែលមានសមត្ថភាពខ្ពស់ ប្រកបដោយភាពច្នៃប្រឌិត និងគំនិតបង្កើតថ្មី បម្រើការងារក្នុង ឬក្រៅតំបន់អាស៊ាន ចូលរួមពង្រឹងឧត្តមភាពប្រកួតប្រជែង និងបង្កើនមូលធនមនុស្សក្នុងវិស័យទេសចរណ៍កម្ពុជា ស្របតាមតម្រូវការនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងទីផ្សារការងារ**" ដោយបានតាក់តែងនូវគោលបំណង ចំនួន ៣ គោលដៅ ចំនួន ៦ ទិសដៅយុទ្ធសាស្ត្រ ចំនួន ៣ សកម្មភាពយុទ្ធសាស្ត្រ ចំនួន ៧។

ក្នុងនាមក្រសួងទេសចរណ៍ ខ្ញុំមានសង្ឃឹមយ៉ាងមុតមាំថា គ្រឹះស្ថានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ ប្រតិបត្តិករទេសចរណ៍ អ្នកជំនាញវិជ្ជាជីវៈទេសចរណ៍ វិស័យឯកជន ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធទាំងអស់ នឹងចូលរួមសហការ អនុវត្តផែនការយុទ្ធសាស្ត្រនេះប្រកបដោយប្រសិទ្ធភាពខ្ពស់ ដើម្បីចូលរួមអភិវឌ្ឍធនធានមនុស្សក្នុងវិស័យទេសចរណ៍ សំដៅធ្វើឱ្យកម្ពុជាក្លាយជាគោលដៅទេសចរណ៍ប្រកបដោយភាពទាក់ទាញ និងផ្តល់ភាពកក់ក្តៅដល់ភ្ញៀវទេសចរ។

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៧

**គណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍**

**ប្រធាន**

**ថោង ខុន**

**រដ្ឋមន្ត្រីក្រសួងទេសចរណ៍**

# មាតិកា

**ផ្នែកទី ១÷ សេចក្តីផ្តើម** ..... ២
១.១ ចក្ខុវិស័យ ..... ៤
១.២ គោលបំណង ..... ៥
១.៣ គោលដៅ ..... ៥
១.៤ តារាងសង្ខេបផែនការយុទ្ធសាស្ត្រ ..... ៦
**ផ្នែកទី ២ ÷ ការវិភាគបច្ចុប្បន្នភាពនៃទីផ្សារការងារ និងការអភិវឌ្ឍជំនាញទេសចរណ៍** ..... ៧
២.១ ស្ថានភាពទេសចរណ៍កម្ពុជា ..... ៧
២.២ ស្ថានភាពទីផ្សារការងារទេសចរណ៍កម្ពុជា ..... ៧
២.២.១ តម្រូវការការងារ ..... ៨
២.២.២ ការផ្គត់ផ្គង់ការងារ ..... ៨
២.៣ ការអភិវឌ្ឍន៏ជំនាញទេសចរណ៍នៅកម្ពុជា ..... ៩
២.៣.១ ការអភិវឌ្ឍជំនាញទេសចរណ៍ជាតិ ..... ៩
២.៣.១ ការអភិវឌ្ឍជំនាញទេសចរណ៍អាស៊ាន ..... ១០
**ផ្នែកទី ៣ ÷ ទិសដៅយុទ្ធសាស្ត្រ ២០១៧-២០២៥** ..... ១១
៣.១ ទិសដៅយុទ្ធសាស្ត្រទី ១៖ បន្តពង្រឹងការអនុវត្តកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកលើអ្នកជំនាញទេសចរណ៍អាស៊ាន ..... ១២
៣.២ ទិសដៅយុទ្ធសាស្ត្រទី ២៖ អភិវឌ្ឍ និងពង្រឹងជំនាញវិជ្ជាជីវៈទេសចរណ៍តាមស្តង់ដាជាតិ និងតម្រូវការនៃការអភិវឌ្ឍន៏វិស័យទេសចរណ៍កម្ពុជា ..... ១៤
៣.៣ ទិសដៅយុទ្ធសាស្ត្រទី ៣៖ ពង្រឹងសមត្ថភាពស្ថាប័ន មន្ត្រីជំនាញ និងភាពជាដៃគូរដ្ឋ-ឯកជនដើម្បីជំរុញការអប់រំបណ្តុះបណ្តាល ..... ១៥
**ផ្នែកទី ៤ ÷ ផែនការអនុវត្តសកម្មភាព** ..... ១៨
៤.១ ទិសដៅយុទ្ធសាស្ត្រទី១៖ បន្តពង្រឹងការអនុវត្តកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកលើអ្នកជំនាញទេសចរណ៍អាស៊ាន ..... ១៨
៤.២ ទិសដៅយុទ្ធសាស្ត្រទី២៖ អភិវឌ្ឍ និងពង្រឹងជំនាញវិជ្ជាជីវៈទេសចរណ៍តាមស្តង់ដាជាតិ និងតម្រូវការនៃការអភិវឌ្ឍវិស័យទេសចរណ៍កម្ពុជា ..... ២១
៤.៣ ទិសដៅយុទ្ធសាស្ត្រទី៣៖ ពង្រឹងសមត្ថភាពស្ថាប័ន មន្ត្រីជំនាញ និងភាពជាដៃគូរដ្ឋ-ឯកជនដើម្បីជំរុញការអប់រំបណ្តុះបណ្តាល ..... ២៣
**ផ្នែកទី ៥ ÷ ការតាមដានត្រួតពិនិត្យការអនុវត្ត និងការវាយតម្លៃ** ..... ៣០
**ផ្នែកទី ៦ ÷ សេចក្តីសន្និដ្ឋាន** ..... ៣១
**សន្ទានុក្រម**
**ឧបសម្ព័ន្ធ**

## ផ្នែកទី ១៖ សេចក្តីផ្តើម

វិស័យទេសចរណ៍ ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាចាត់ទុកជា**មាសបៃតង** និង**ជាការនាំចេញនៅនឹងកន្លែង**។ វិស័យនេះចូលរួមអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម តាមរយៈការបង្កើតប្រាក់ចំណូលជូនជាតិ បង្កើតការងារ ទាក់ទាញការវិនិយោគ និងចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។ លើសពីនេះទៀត ទេសចរណ៍ក៏បានចូលរួមចំណែកលើកកម្ពស់ ថែរក្សា និងអភិរក្សសម្បត្តិវប្បធម៌ និងធម្មជាតិរបស់ប្រទេស ចូលរួមកាត់បន្ថយការកើនឡើងនៃកំដៅភពផែនដី និងជា**កាតាលីករមួយដ៏សំខាន់**ក្នុងការជំរុញសាកលភាវូបនីយកម្ម និងសមាហរណកម្មតំបន់ផងដែរ។

នាទសវត្សរ៍ចុងក្រោយនេះ ទេសចរណ៍ត្រូវបានសកលលោកចាត់ទុកជាវិស័យដែលមាន**ភាពធន់នឹងវិបត្តិ** (Resilient)។ ជាក់ស្តែង ទោះមានសង្គ្រាមក្នុងប្រទេសមួយចំនួន វិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសកលលោក ការគំរាមកំហែងដោយភារវកម្ម និងជំងឺរាតត្បាត ទេសចរណ៍ពិភពលោកនៅតែមានកំណើនលើសការរំពឹងទុក ដោយនៅ**ឆ្នាំ២០១៣** មានចំនួន **១.០៨៨ លាននាក់ ឆ្នាំ២០១៤** មានចំនួន **១.១៣៤ លាននាក់ ឆ្នាំ២០១៥** មានចំនួន **១.១៨៦ លាននាក់** និង**ឆ្នាំ២០១៦ មានចំនួន១,២៣៥លាននាក់ ក្នុងកំណើនជាង ៤%** ហើយនៅ **ឆ្នាំ២០២០** និង **ឆ្នាំ២០៣០** ទេសចរណ៍ពិភពលោកនឹងកើនដល់ **១.៦០០ លាននាក់ និង ១.៨០០ លាននាក់** ។

យោងតាមរបាយការណ៍របស់អង្គការទេសចរណ៍ពិភពលោក (UNWTO) និងក្រុមប្រឹក្សាទេសចរណ៍ និងធ្វើដំណើរពិភពលោក (WTTC) **ឆ្នាំ២០១៦** ឧស្សាហកម្មទេសចរណ៍ និងធ្វើដំណើរបានបង្កើតការងារសរុប (ផ្ទាល់ និងប្រយោល) ប្រមាណ **២៩២លាននាក់** (ផ្ទាល់មានចំនួន **១០៩លាននាក់**)។ ពោលក្នុងចំណោមការងារ **ចំនួន ១០ មានការងារ ១** ស្ថិតក្នុងឧស្សាហកម្មនេះ។ វិស័យទេសចរណ៍ និងធ្វើដំណើរក៏បានបង្កើតចំណូលជាតិបាន **៧,៦ទ្រីលាន** ដុល្លារអាមេរិក ស្មើនឹង **១០%** នៃផលិតផលក្នុងស្រុកសរុប (GDP)។ ចំណូលពីវិស័យទេសចរណ៍ និងធ្វើដំណើរស្មើនឹង **៣០% នៃការនាំចេញផ្នែកសេវាកម្ម** និងជាង **៧% នៃការនាំចេញសរុប។** វិស័យនេះនៅតែស្ថិតក្នុង**លំដាប់លេខ ៣ នៃការនាំចេញពិភពលោក** បន្ទាប់ពីការនាំចេញប្រេងឥន្ធនៈ និងផលិតផលគីមី នាំមុខការនាំចេញរថយន្ត និងផលិតផលចំណីអាហារ។

ក្នុងបរិបទអាស៊ានឆ្នាំ២០១៦ ប្រទេសជាសមាជិកអាស៊ានបានទទួលទេសចរអន្តរជាតិចំនួន **១១៦លាននាក់** កើនឡើង **៦,៥%** ក្នុងនោះទេសចរផ្ទៃក្នុងអាស៊ាន (Intra-ASEAN Travelers) មានចំនួនជាង **៥៣,៣ លាននាក់** កើន **៦,៥%**។ ទេសចរណ៍អាស៊ានបានបង្កើតចំណូលជូនជាតិប្រមាណ **១២%** នៃផលិតផលក្នុងស្រុកសរុប (GDP) និងការងារសរុបប្រមាណ **៤៥លាននាក់** ក្នុងនោះការងារផ្ទាល់មានប្រមាណ **១៣ លាននាក់**។ ជាចក្ខុវិស័យ ឆ្នាំ២០២០ អាស៊ានរំពឹងទទួលបានទេសចរអន្តរជាតិប្រមាណ **១២៣លាននាក់**។

ផ្តើមចេញពីយុទ្ធសាស្ត្រឈ្នះ-ឈ្នះ របស់ ***សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា*** នៅឆ្នាំ១៩៩៨ កម្ពុជាបានទទួលសុខសន្តិភាពពេញបរិបូរណ៍ ការបង្រួបបង្រួមជាតិ ស្ថេរភាពនយោបាយ សន្តិសុខ និងសុវត្ថិភាពសង្គមពេញផ្ទៃប្រទេស ដែលជាកត្តាមូលដ្ឋានសម្រាប់ការអភិវឌ្ឍលើគ្រប់វិស័យ។ រាជរដ្ឋាភិបាលកម្ពុជាបានស្តារមូលដ្ឋានសេដ្ឋកិច្ចសង្គមវប្បធម៌របស់ខ្លួនឡើងវិញ បន្ទាប់ពីត្រូវបានបំផ្លិចបំផ្លាញដោយសង្គ្រាមស៊ីវិលអូសបន្លាយ ដូចជាការអភិវឌ្ឍធនធានមនុស្ស ហេដ្ឋារចនាសម្ព័ន្ធ និងការអភិវឌ្ឍវិស័យសេដ្ឋកិច្ចផ្សេងៗទៀត ដោយត្រូវដោះស្រាយបញ្ហាប្រឈមនានារាប់មិនអស់។ នាពេល

បច្ចុប្បន្ននេះ កម្ពុជាមានការរីកចម្រើនលើគ្រប់វិស័យ ដោយធានាបាននូវ កំណើនសេដ្ឋកិច្ច ជាមធ្យម **៧,៧%** អត្រាគ្មានការងារធ្វើបានធ្លាក់ចុះ ភាពក្រីក្រធ្លាក់ចុះ ជាពិសេស កម្ពុជាបានក្លាយពីប្រទេសដែលមានចំណូលទាប ទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប។ សមិទ្ធិផលទាំងនេះ បានមកពីកិច្ចខិតខំនិងមាគ៌ាដឹកនាំដ៏ឈ្លៀសវៃរបស់រាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍជាតិលើគ្រប់វិស័យ ក្នុងនោះរួមមានវិស័យទេសចរណ៍ ផងដែរ។

ជាក់ស្តែង កម្ពុជាបានទទួលទេសចរអន្តរជាតិចំនួន **២៩ម៉ឺននាក់**នៅឆ្នាំ១៩៩៨ និងមានកំណើនយ៉ាងឆាប់រហ័សរហូតដល់ជាង ៥លាននាក់ នៅឆ្នាំ២០១៦ ដែលនាំចំណូលចូលសេដ្ឋកិច្ចជាងប្រមាណ **៣៤០០ លានដុល្លារអាមេរិក** ស្មើនឹង ១៣%នៃផលិតផលក្នុងស្រុកសរុប (GDP)។ យោងតាមរបាយការណ៍របស់ក្រុមប្រឹក្សាទេសចរណ៍ និងធ្វើដំណើរពិភពលោក (WTTC) ឆ្នាំ២០១៦ វិស័យទេសចរណ៍ និងធ្វើដំណើរកម្ពុជាបានបង្កើតការងារផ្ទាល់ និងមិនផ្ទាល់សរុបចំនួនជាង **២,២លាននាក់** ស្មើនឹង **២៦%**នៃការងារសរុប ក្នុងនោះការងារផ្ទាល់មានប្រមាណ **១លាននាក់** ស្មើ**១២%** នៃការងារសរុប ហើយការងារផ្ទាល់នៅក្នុងវិស័យទេសចរណ៍មានប្រមាណជាង **៦២ម៉ឺននាក់**។ តាមការព្យាករណ៍របស់ក្រុមប្រឹក្សាទេសចរណ៍ និងធ្វើដំណើរពិភពលោក (WTTC) ឆ្នាំ២០២៥ វិស័យទេសចរណ៍ និង ធ្វើដំណើរកម្ពុជានឹងបង្កើតការងារផ្ទាល់ប្រមាណ **១,៦លាន**នាក់ ក្នុងកំណើនមធ្យមប្រចាំឆ្នាំ **៤,៨%**។ ជាចក្ខុវិស័យ នៅឆ្នាំ២០២០ វិស័យទេសចរណ៍កម្ពុជាសង្ឃឹមថានឹងទទួលបានទេសចរបរទេសប្រមាណ **៧លាននាក់** នាំចំណូលចូលជាតិប្រមាណ **៥ពាន់លានដុល្លារ** និងបង្កើតការងារបានប្រមាណជិត**១លាននាក់**។

ដើម្បីសម្រេចចក្ខុវិស័យ និងគោលដៅយុទ្ធសាស្ត្រខាងលើ ក្រសួងទេសចរណ៍បានដាក់ចេញនូវចលនាប្រឡងប្រណាំង "**ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ និងបដិសណ្ឋារកិច្ចល្អ**" សំដៅលើកកម្ពស់ការយល់ដឹងសាធារណៈ ការចូលរួមរបស់សាធារណៈជន និងប្រតិបត្តិករទេសចរណ៍ ក្នុងការអនុវត្តស្តង់ដាគុណភាព ការបណ្តុះបណ្តាលជំនាញ ការអនុវត្តច្បាប់ និងបទដ្ឋានគតិយុត្តនានារបស់ក្រសួងទេសចរណ៍។ ទាក់ទងនឹងការអភិវឌ្ឍជំនាញទេសចរណ៍ ក្រសួងបានដាក់ចេញនូវយុទ្ធនាការ "**បុគ្គលិកម្នាក់ ជំនាញមួយ**" អមដោយការជំរុញឲ្យមាន**ការបណ្តុះបណ្តាលខាងក្នុង** តាមអង្គភាពអាជីវកម្មដោយអ្នកគ្រប់គ្រង ឬម្ចាស់អាជីវកម្មដល់បុគ្គលិករបស់ខ្លួន ដោយក្រសួងបានផ្តល់នូវជំនួយបច្ចេកទេសចាំបាច់ផ្សេងៗ។

ក្រសួងទេសចរណ៍បានចាត់ទុកការបណ្តុះបណ្តាល និងការអភិវឌ្ឍមូលធនមនុស្ស ជាមូលដ្ឋានយុទ្ធសាស្ត្រ នៃការពង្រឹងគុណភាពសេវាកម្ម ការផ្តល់សេវាប្រកបដោយសេចក្តីពេញចិត្តដល់ទេសចរ បង្កើនផលិតភាពការងារ ចូលរួមពង្រឹងឧត្តមភាពប្រកួតប្រជែង ជំរុញការបង្កើតថ្មី និងភាពច្នៃប្រឌិត ទ្រទ្រង់និរន្តរភាពនៃកំណើន ធានាបាននូវការអភិវឌ្ឍប្រកបដោយបរិយាប័ន្ន ព្រមទាំងចូលរួមថែរក្សា ការពារ និងលើកកម្ពស់សម្បត្តិវប្បធម៌ និងធនធានធម្មជាតិរបស់ប្រទេស។

ដោយអនុវត្តតាមគោលការណ៍ខាងលើ ក្រសួងបានជំរុញការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចណ៍ និងការអប់រំអំពីទេសចរណ៍ដល់ប្រតិបត្តិករទេសចរណ៍ទាំងអស់ ដែលស្ថិតក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ទេសចរណ៍ មានដូចជា ការបណ្តុះបណ្តាលដល់បុគ្គលិក និងមន្ត្រីច្រកទ្វារព្រំដែន និងតាមព្រលានយន្តហោះ ការបណ្តុះបណ្តាលដល់បុគ្គលិកសេវាកម្មដឹកជញ្ជូន មគ្គុទ្ទេសក៍ទេសចរណ៍ អ្នកជំនាញតាមសណ្ឋាគារ ភោជនីយដ្ឋានទីភ្នាក់ងារទេសចរណ៍ ការីទេសចរណ៍ អាជីវករតាមរមណីយដ្ឋាន បុគ្គលិកស្ប៉ា-ម៉ាស្សា បុគ្គលិកតាមមណ្ឌលកំសាន្ត អ្នកបម្រើការងារតាមសហគមន៍ទេសចរណ៍ និងបុគ្គលិកសេវាកម្មផ្សេងៗទៀត។

ការអប់រំ និងបណ្តុះបណ្តាលជំនាញរយៈពេលខ្លី និងវែងក៏ត្រូវបានផ្តល់ដោយសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ សាកលវិទ្យាល័យ អង្គការជាតិ និងអន្តរជាតិផងដែរ។ ជាលទ្ធផល គុណភាពសេវាកម្មទេសចរណ៍កម្ពុជាត្រូវបានវាយតម្លៃខ្ពស់ និងទទួលបានការពេញចិត្តពីទេសចរ ដូចដែលបានបង្ហាញតាមរយៈលទ្ធផលនៃការវាយតម្លៃពីស្ថាប័នទេសចរណ៍អន្តរជាតិដូចជា Trip Advisor ជាដើម។ ទន្ទឹមនឹងនេះផងដែរ ប្រជាពលរដ្ឋខ្មែរត្រូវបានទទួលស្គាល់ថាជាប្រជាពលរដ្ឋប្រកបដោយស្នាមញញឹម មានភាពរួសរាយរាក់ទាក់ ស្មោះត្រង់ សុភាពរាបសារ ដែលទាំងនេះជាសម្បត្តិមូលដ្ឋាននៃការផ្តល់បដិសណ្ឋារកិច្ចល្អ។

ក្នុងស្មារតីនៃការអភិវឌ្ឍជំនាញទេសចរណ៍ ក្រសួងទេសចរណ៍ក៏បានជំរុញការបង្កើតសាលាបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ កម្មវិធីបណ្តុះបណ្តាលខ្លីៗ ការបណ្តុះបណ្តាលគ្រូបង្គោល អ្នកវាយតម្លៃបង្គោល ដល់សាលាបណ្តុះបណ្តាល និងអង្គភាពអាជីវកម្មទេសចរណ៍ ផ្តល់ឯកសារបណ្តុះបណ្តាល និងជំនួយបច្ចេកទេសផ្សេងៗទៀតដល់ស្ថាប័ន ឬកម្មវិធីបណ្តុះបណ្តាល។ កិច្ចសហការជាមួយស្ថាប័នអន្តរជាតិ ដៃគូរអភិវឌ្ឍន៍ នានាក៏ត្រូវបានពង្រឹង និងពង្រីកលើផ្នែកអភិវឌ្ឍនធនធានមនុស្សនេះ តាមរយៈកិច្ចសហប្រតិបត្តិការលើការបង្កើតសាលាបណ្តុះបណ្តាល ឬកម្មវិធីបណ្តុះបណ្តាល ជំនួយឧបត្ថម្ភ និងទស្សនកិច្ចសិក្សាជាដើម។

ក្នុងក្របខ័ណ្ឌតំបន់ ក្រសួងទេសចរណ៍មានគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍ ជាសេនាធិការបាននឹងកំពុងយកចិត្តទុកដាក់ខ្ពស់ ក្នុងការអនុវត្តស្មារតីនៃកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកលើអ្នកជំនាញទេសចរណ៍អាស៊ាន (ASEAN MRA TP) ដែលមានគោលដៅសម្រួលបម្លាស់ទីការងាររបស់អ្នកជំនាញក្នុងផ្នែកសេវាកម្មសណ្ឋាគារ និងសេវាកម្មធ្វើដំណើរ ក្នុងតំបន់អាស៊ានស្របតាមស្មារតីនៃសមាហរណកម្មតំបន់ ព្រមទាំងចូលរួមអភិវឌ្ឍជំនាញទេសចរណ៍ក្នុងប្រទេសសមាជិកអាស៊ានរួមគ្នា សំដៅធ្វើឲ្យតំបន់អាស៊ានក្លាយជាគោលដៅទេសចរណ៍តែមួយប្រកបដោយគុណភាពកម្រិតខ្ពស់។ តាមរយៈការអនុវត្តកិច្ចព្រមព្រៀងនេះ កម្ពុជាបានផ្លាស់ប្តូរបទពិសោធន៍ល្អៗជាមួយប្រទេសជាសមាជិកលើការអភិវឌ្ឍធនធានមនុស្ស ចូលរួមអនុវត្តយន្តការរួមអាស៊ានស្តីពីការបណ្តុះបណ្តាល និងវាយតម្លៃទទួលស្គាល់អ្នកជំនាញ។

ជាយុទ្ធសាស្ត្រក្នុងការជំរុញកំណើនប្រកបដោយនិរន្តរភាព ក្រសួងទេសចរណ៍បានផ្តោតការយកចិត្តទុកដាក់ខ្ពស់ជាអាទិភាពលើការអភិវឌ្ឍធនធានមនុស្ស សំដៅធ្វើឲ្យអ្នកជំនាញមានសមត្ថភាពខ្ពស់ស្របតាមស្តង់ដាជាតិ និងអាស៊ាន ឆ្លើយតបនឹងតម្រូវការជំនាញទេសចរណ៍ ដែលកាន់តែកើនឡើងជាលំដាប់។ អាទិភាពក៏ផ្តោតផងដែរ លើការលើកកម្ពស់វិជ្ជាជីវៈទេសចរណ៍ ការជំរុញឲ្យមានកំណើននៃជំនាញ ចំណេះដឹង ការបង្កើតថ្មី និងភាពច្នៃប្រឌិត ទាំងបរិមាណ និងគុណភាព ក្នុងវិស័យទេសចរណ៍កម្ពុជា ដើម្បីបង្កើនភាពប្រកួតប្រជែងរបស់ខ្លួនឲ្យកាន់តែខ្លាំងថែមទៀត។

ក្នុងន័យនេះ **"ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យទេសចរណ៍ ២០១៧-២០២៥"** ត្រូវបានរៀបចំឡើង ដើម្បីជាផែនទីតម្រង់ទិសក្នុងការអភិវឌ្ឍន៍ជំនាញ និងមូលធនមនុស្សក្នុងវិស័យទេសចរណ៍ ដោយបានកំណត់ចក្ខុវិស័យច្បាស់លាស់ ព្រមទាំងដាក់ចេញទិសដៅ និងសកម្មភាពជាយុទ្ធសាស្ត្រ សំដៅចូលរួមបង្កើតការងារយូរអង្វែងដល់យុវជនបញ្ចប់ការសិក្សា ផ្តល់ការអភិវឌ្ឍជំនាញបន្ថែមដល់អ្នកកំពុងបម្រើការងារ បង្កើនកាលានុវត្តភាពការងារក្នុង និងក្រៅប្រទេស ដោយផ្តោតលើការអប់រំបណ្តុះបណ្តាលផ្នែកចំណេះដឹង ជំនាញ និងអត្តចរិក។

## ១.១ ចក្ខុវិស័យ

**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យទេសចរណ៍ ២០១៧-២០២៥** មានចក្ខុវិស័យ ដូចតទៅ៖

*"នៅឆ្នាំ២០២៥ កម្ពុជានឹងមានអ្នកជំនាញទេសចរណ៍ ដែលមានសមត្ថភាពខ្ពស់ ប្រកបដោយភាពច្នៃប្រឌិត និង គំនិតបង្កើតថ្មី បម្រើការងារក្នុង ឬក្រៅតំបន់អាស៊ាន ចូលរួមពង្រឹងឧត្តមភាពប្រកួតប្រជែង និងបង្កើន មូលធនមនុស្សក្នុងវិស័យទេសចរណ៍កម្ពុជា ស្របតាមតម្រូវការនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងទីផ្សារការងារ"*

## ១.២ គោលបំណង

ផែនការយុទ្ធសាស្ត្រនេះមានគោលបំណងដើម្បីៈ

១. អប់រំបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពសិស្ស-និស្សិត និងអ្នកបម្រើការងារក្នុងវិស័យទេសចរណ៍កម្ពុជា ឲ្យមានចំណេះដឹង ជំនាញច្បាស់លាស់ និងអត្តចរិកល្អប្រសើរ ឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងទីផ្សារការងារ ដែលមានការប្រែប្រួលយ៉ាងឆាប់រហ័ស។

២. បណ្តុះបណ្តាល និងពង្រឹងសមត្ថភាពមន្ត្រីជំនាញក្នុងការចូលរួមអនុវត្តច្បាប់ គោលនយោបាយ និងបទដ្ឋានគតិយុត្តផ្សេងៗ។

៣. លើកកម្ពស់គុណតម្លៃជំនាញវិជ្ជាជីវៈទេសចរណ៍កម្ពុជា សំដៅជំរុញ និងទាក់ទាញការជ្រើសរើសជំនាញទេសចរណ៍ជាវិជ្ជាជីវៈប្រចាំជីវិត។

## ១.៣ គោលដៅ

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យទេសចរណ៍ ២០១៧-២០២៥** មានគោលដៅដូចតទៅៈ

១. ការអប់រំបណ្តុះបណ្តាលជំនាញឆ្លើយតបតាមស្តង់ដាកម្មវិធីសិក្សាជាតិ និងអាស៊ាន ជាកម្រិតអប្បរមា ស្របតាមតម្រូវការនៃការភិវឌ្ឍវិស័យទេសចរណ៍ជាតិ តំបន់ និងសាកលលោក ក៏ដូចជាតម្រូវការទីផ្សារការងារបច្ចុប្បន្ន។

២. អ្នកបម្រើការងារក្នុងវិស័យទេសចរណ៍កម្ពុជាមានសមត្ថភាពពេញលេញ ដែលរួមមានចំណេះដឹងទូលំទូលាយ ជំនាញច្បាស់លាស់ និងអត្តចរិកល្អ ប្រកបដោយភាពច្នៃប្រឌិតខ្ពស់ និងសហគ្រិនភាព។

៣. យុវជនមានការយល់ដឹងទូលំទូលាយកាន់តែប្រសើរថែមទៀត អំពីវិធីនៃការអភិវឌ្ឍជំនាញទេសចរណ៍ កំណើននៃការជ្រើសរើសយកជំនាញទេសចរណ៍ ហើយគុណវុឌ្ឍិរបស់អ្នកបម្រើការងារត្រូវបានទទួលស្គាល់ក្នុងក្របខ័ណ្ឌគុណវុឌ្ឍិជាតិ និងអាស៊ាន។

៤. អ្នកជំនាញកម្ពុជាមានសមត្ថភាពខ្ពស់ មានលទ្ធភាពបម្រើការក្នុងទីផ្សារការងារក្នុង និងក្រៅតំបន់អាស៊ាន ដែលមានការប្រកួតប្រជែងខ្លាំង។

៥. មន្ត្រីជំនាញមានសមត្ថភាពខ្ពស់ ក្នុងការដឹកនាំ និងគ្រប់គ្រងឧស្សាហកម្មទេសចរណ៍

៦. គ្រប់ភាគីពាក់ព័ន្ធចូលរួមសហការក្នុងកិច្ចការអភិវឌ្ឍវិស័យទេសចរណ៍ប្រកដោយប្រសិទ្ធភាពខ្ពស់

## ១.៤ តារាងសង្ខេបផែនការយុទ្ធសាស្ត្រ

**នៅឆ្នាំ២០២៥ កម្ពុជានឹងមានអ្នកជំនាញទេសចរណ៍ ដែលមានសមត្ថភាពខ្ពស់ ប្រកបដោយភាពច្នៃប្រឌិត និងគំនិតបង្កើតថ្មី បម្រើការងារក្នុង ឬក្រៅតំបន់អាស៊ាន ចូលរួមពង្រឹងឧត្តមភាពប្រកួតប្រជែងនិងបង្កើនមូលធនមនុស្សក្នុងវិស័យទេសចរណ៍កម្ពុជា ស្របតាមតម្រូវការនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងទីផ្សារការងារ**

| ទិសដៅយុទ្ធសាស្ត្រ | | |
|---|---|---|
| បន្តពង្រឹងការអនុវត្តកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកលើអ្នកជំនាញទេសចរណ៍អាស៊ាន (MRA-TP) | អភិវឌ្ឍ និងពង្រឹងជំនាញវិជ្ជាជីវៈទេសចរណ៍តាមស្តង់ដាជាតិ និងតម្រូវការនៃការអភិវឌ្ឍវិស័យទេសចរណ៍ | ពង្រឹងសមត្ថភាព ស្ថាប័ន មន្ត្រីជំនាញ និងភាពជាដៃគូរដ្ឋ-ឯកជនដើម្បីជំរុញការអប់រំបណ្តុះបណ្តាល |

| សកម្មភាពយុទ្ធសាស្ត្រ | | |
|---|---|---|
| បណ្តុះបណ្តាល និងពង្រឹងសមត្ថភាពអ្នកជំនាញទេសចរណ៍ស្របតាមស្តង់ដាជាតិ និងអាស៊ាន | រៀបចំ និងអនុវត្តស្តង់ដាបណ្តុះបណ្តាលជាតិ តាមជំនាញ | បណ្តុះបណ្តាល និងពង្រឹងសមត្ថភាពស្ថាប័ន និងមន្ត្រីជំនាញ |
| ជំរុញការវាយតម្លៃទទួលស្គាល់សមត្ថភាពអ្នកជំនាញទេសចរណ៍ | បន្តពង្រឹងចំណេះដឹង និងការយល់ដឹងសាធារណៈ អំពីវិស័យទេសចរណ៍ | ពង្រឹងភាពជាដៃគូរដ្ឋ-ឯកជន ដើម្បីចូលរួមអភិវឌ្ឍ និងធានានិរន្តរភាពនៃការអប់រំបណ្តុះបណ្តាល |
| បង្កើនឱកាសការងារ និងលទ្ធភាពបម្លាស់ទីការងារ | | |

## ផ្នែកទី ២ ៖

## ការវិភាគបច្ចុប្បន្នភាពនៃទីផ្សារការងារ និងការអភិវឌ្ឍជំនាញទេសចរណ៍

### ២.១ ស្ថានភាពទេសចរណ៍កម្ពុជា

ក្រសួងទេសចរណ៍បានដាក់ចុះនូវយុទ្ធនាការ **"កម្ពុជា៖ ព្រះរាជាណាចក្រអច្ឆរិយៈ ផ្តល់ភាពកក់ក្តៅ"** និងចលនាប្រឡងប្រណាំង **"ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ និងបដិសណ្ឋារកិច្ចល្អ"** សំដៅធ្វើឲ្យកម្ពុជាក្លាយជាគោលដៅទេសចរណ៍ប្រកបដោយភាពទាក់ទាញ និងផ្តល់ភាពកក់ក្តៅដល់ទេសចរ ដោយឈរលើទស្សនទាន **"ស្អាត និងបៃតង"** និងគោលការណ៍នៃការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តភាព និងការទទួលខុសត្រូវ។ នៅឆ្នាំ២០១៦ យើងសម្រេចបានកំណើនក្នុងអត្រា **៥%** ជាមួយនឹងការមកដល់នៃភ្ញៀវទេសចរអន្តរជាតិជាង**៥លាននាក់** និងនាំប្រាក់ចំណូលប្រមាណ **៣.៤០០លានដុល្លារអាមេរិក** ចាក់បញ្ចូលក្នុងសេដ្ឋកិច្ចជាតិ ស្មើនឹង ១៣% នៃផលិតផលក្នុងស្រុកសរុប (GDP)។ នៅឆ្នាំ២០១៧ ការមកដល់នៃភ្ញៀវទេសចរអន្តរជាតិអាចនឹងប្រមាណ **៥លាន៤សែននាក់** ហើយ នៅឆ្នាំ២០២០ ចំនួននេះអាចនឹងកើនឡើងដល់**៧លាននាក់** និងនាំមកនូវចំណូលសរុបចូលសេដ្ឋកិច្ចជាតិប្រមាណ **៥.០០០លានដុល្លារអាមេរិក** បង្កើតការងារផ្ទាល់បានប្រមាណ**១លាននាក់**។

រយៈពេល ០៧ខែដើមឆ្នាំ២០១៧នេះ កម្ពុជាបានទទួលទេសចរអន្តរជាតិចំនួន **៣.១០៩.៣០៦នាក់** កើនឡើង **១២,៦%** ធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០១៦ ដោយក្នុងនោះ តាមផ្លូវអាកាសមានចំនួន **៦០,៣%** កើន **២៣,៦%** តាមផ្លូវគោកមានចំនួន **៣៦,៦%** ថយចុះ **០,៦%** និងតាមផ្លូវទឹកមានចំនួន **៣,១%** កើន **០,៦%**។

សម្រាប់រយៈពេលខាងលើ ទីផ្សារទេសចរណ៍សំខាន់ៗទាំង១០របស់កម្ពុជារួមមាន ចិន វៀតណាម ឡាវ កូរ៉េ ថៃ អាមេរិក ជប៉ុន អង់គ្លេស បារាំង និងម៉ាឡេស៊ី។ ក្នុងចំណោមទីផ្សារទាំងនេះ ទេសចរចិន (**លំដាប់លេខ១**) មានចំនួនជាង **៦៣ម៉ឺននាក់ កើន ៤២,៧%** វៀតណាម (**លេខ២**) មានចំនួនជាង **៤៧ម៉ឺននាក់ កើន ១៤,៨%** ឡាវ (**លេខ៣**) មានចំនួនជាង **២៦ម៉ឺននាក់** កើន **៧៧,៣%**។ ជារួម កម្ពុជាបានទទួលទេសចរពីតំបន់អាស៊ីប៉ាស៊ីហ្វិកប្រមាណ **៧៥,៣%** កើន **១២,៤%** (ក្នុងនោះមកពីតំបន់អាស៊ាន **៣៧,៤%** កើន **៤%**) មកពីតំបន់អឺរ៉ុបចំនួន **១៦,២%** កើន **១៣,៥%** និងមកពីអាមេរិក **៧,៨%** កើន **១៤,៣%**។

រយៈពេល ០៧ខែនេះដែរ តំបន់ភ្នំពេញទទួលបានទេសចរអន្តរជាតិជិត **១,៧លាននាក់** (**៤៦,៨%**) កើន **១៣,៥%** តំបន់សៀមរាបអង្គរបានចំនួនជាង **១,៤លាននាក់** (**៣៩,២%**) កើន **១២%** តំបន់ឆ្នេរសមុទ្រទទួលបានចំនួនជាង **៤៦ម៉ឺននាក់** (**១២,៩%**) កើន **១៧,៥%** តំបន់អេកូទេសចរណ៍ភូមិភាគឥសាន្តចំនួន **៤,៣ម៉ឺននាក់** (**១,២%**) កើន **៨,៥%** និងតំបន់ប្រាសាទព្រះវិហារទទួលបានជាង **៣,៥ម៉ឺននាក់** កើន **១៧,៩%**។ រីឯទេសចរកម្ពុជាចេញទៅទស្សនានៅក្រៅប្រទេសមានប្រមាណ **១លាននាក់ កើន២២,៥%**។

### ២.២ ស្ថានភាពទីផ្សារការងារទេសចរណ៍កម្ពុជា

ស្របពេលជាមួយនឹងកំណើនឡើងជាលំដាប់របស់ភ្ញៀវទេសចរអន្តរជាតិ វិស័យទេសចរណ៍បានផ្តល់នូវឱកាសការងារជាច្រើនដល់យុវជនកម្ពុជា នឹងចូលរួមចំណែកដល់ការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនស្របតាមផែនការយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលកម្ពុជា។ កម្ពុជាកំពុងតែមានការចាប់អារម្មណ៍កាន់តែខ្លាំងឡើងលើជំនាញវិជ្ជាជីវៈទេសចរណ៍ ប៉ុន្តែកង្វះសាលាបណ្តុះបណ្តាលជំនាញនេះធ្វើឲ្យការផ្គត់ផ្គង់ជំនាញមិនបានគ្រប់គ្រាន់ឆ្លើយតបនឹងសេចក្តីត្រូវការទីផ្សារ។ ក្នុងន័យនេះក្រសួងទេសចរណ៍បានខិតខំជំរុញឲ្យមានការបង្កើតសាលាបណ្តុះបណ្តាល និងវគ្គបណ្តុះបណ្តាលខ្លី ឬវែងគ្រប់ទម្រង់។

### ២.២.១.តម្រូវការការងារ

នៅឆ្នាំ២០២០ កម្ពុជាត្រូវការអ្នកជំនាញវិជ្ជាជីវៈទេសចរណ៍ប្រមាណជិត **១លាននាក់** ដើម្បីបម្រើការងារដោយផ្ទាល់ ជូនភ្ញៀវទេសចរដែលនឹងកើនឡើងប្រមាណ **៧លាននាក់**។ ដូចនេះ ក្រសួងទេសចរណ៍ត្រូវជំរុញឲ្យមានការបណ្តុះបណ្តាលកម្លាំងពលកម្មថ្មីចំនួនប្រមាណជាង **៥ម៉ឺននាក់** ក្នុងមួយឆ្នាំចាប់ពីឆ្នាំ២០១៧តទៅ។ ទន្ទឹមនឹងនេះដែរ នាពេលបច្ចុប្បន្ន អ្នកកំពុងបម្រើការងារមានចំនួនប្រមាណ **២០%** ប៉ុណ្ណោះ ដែលបានឆ្លងកាត់ការសិក្សាជំនាញទេសចរណ៍ តាមសាលាបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ សាកលវិទ្យាល័យទេសចរណ៍ និងវគ្គសិក្សាខ្លីៗ (ដោយមិនគិតការបណ្តុះណ្តាលខាងក្នុង)។ ដូចនេះក្រសួងទេសចរណ៍ត្រូវដោះស្រាយបញ្ហាប្រឈមខាងលើ ពោលគឺត្រូវជំរុញការ**បណ្តុះបណ្តាលកម្លាំងពលកម្មថ្មី** និងបំពាក់**បំប៉នជំនាញបន្ថែមទៀតដល់អ្នកកំពុងបម្រើការងារ**។

កម្ពុជាសម្បូរធនធានមនុស្សដែលអាចបម្រើការងារក្នុងវិស័យទេសចរណ៍កម្ពុជា និងអាចទៅបម្រើការងារនៅក្នុងតំបន់ ប៉ុន្តែយើងជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនដូចជាកង្វះសាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ ដែលមិនអាចផ្គត់ផ្គង់ពលកម្មជំនាញបានគ្រប់គ្រាន់ ក្នុងវិស័យទេសចរណ៍កម្ពុជា។ ក្នុងន័យនេះក្រសួងទេសចរណ៍ បានជំរុញឲ្យមានការបង្កើតសាលាបណ្តុះបណ្តាលជំនាញវិជ្ជាជិវៈទេសចរណ៍ដោយរដ្ឋ និងឯកជន ធ្វើការតម្រង់ទិសស្តីអំពីការអប់រំបណ្តុះបណ្តាលឲ្យស្របទៅតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិ និងអាស៊ាន ដែលធានានូវការអភិវឌ្ឍសមត្ថភាពរបស់អ្នកជំនាញទេសចរណ៍ស្របតាមសេចក្តីត្រូវការជំនាញក្នុងប្រទេស និងតំបន់។ ជាមួយគ្នានេះដែរ ដោយប្រតិបត្តិករទេសចរណ៍មួយចំនួននៅតែគិតថាជំនាញវិជ្ជាជីវៈទេសចរណ៍ ជាការងារតាមរដូវកាល ធ្វើឲ្យតម្រូវការជ្រើសរើសបុគ្គលិក សម្រាប់តែបំពេញសេចក្តីត្រូវការរយៈពេលខ្លី ប្រាក់បៀវត្សនៅមានកម្រិត និងមិនបានយកចិត្តទុកដាក់ខ្ពស់ដល់ការបណ្តុះបណ្តាលបន្ថែមដល់បុគ្គលិករបស់ខ្លួន។ កត្តានេះធ្វើឲ្យអ្នកជំនាញទេសចរណ៍មិនអាចមានឱកាសអភិវឌ្ឍសមត្ថភាពខ្លួននៅកន្លែងការងារ។

ការផ្គត់ផ្គង់ពលកម្មជំនាញអាចនឹងកើនឡើង តាមរយៈការលើកកម្ពស់ការយល់ដឹងពីជំនាញវិជ្ជាជីវៈទេសចរណ៍ដល់ប្រជាជន ជាពិសេសយុវជន អំពីវិថីអភិវឌ្ឍជំនាញទេសចរណ៍ និងឱកាសការងារក្នុងវិស័យទេសចរណ៍។ តម្រូវការការងារក្នុវិស័ទេសចរណ៍អាចមានការប្រែប្រួលទៅតាមទីផ្សារទេសចរណ៍ ដែលទាមទារឲ្យគ្រប់អង្គភាពពាក់ព័ន្ធទាំងអស់សម្របខ្លួន និងពង្រឹងការយល់ដឹងពីទីផ្សារទេសចរណ៍ថ្មីៗប្រកបដោយប្រសិទ្ធភាព។ ជាក់ស្តែងប៉ុន្មានឆ្នាំចុងក្រោយនេះ ទីផ្សារទេសចរចិនបានកើនឡើង ហើយក្លាយជាទីផ្សារធំបំផុតទី០១ ធំជាងគេលើពិភពលោក ហើយក៏ជាទីផ្សាធំជាង់គេបំផុតរបស់កម្ពុជាផងដែរ។ ដូចនេះ តម្រូវការអ្នកចេះភាសាចិនមានការកើនឡើង ដែលទាមទារឲ្យមានការបង្កើនការបណ្តុះបណ្តាលភាសា និងវប្បធម៌ចិន បន្ថែមទៀត ស្របពេលនឹងការបណ្តុះបណ្តាលជំនាញ ដើម្បីចូលរួមបម្រើនិងទាក់ទាញទីផ្សារនេះ។

### ២.២.២ ការផ្គត់ផ្គង់ការងារ

ការផ្គត់ផ្គង់ការងារក្នុងវិស័យទេសចរណ៍មានច្រើនសណ្ឋានរាប់ចាប់ពីជំនាញកម្រិតទាប ដល់ជំនាញកម្រិតខ្ពស់។ ការយល់ដឹងអំពីឱកាសការងារ និងវិថីអភិវឌ្ឍអាជីពការងារនៅក្នុងជំនាញវិជ្ជាជីវៈទេសចរណ៍មិនទាន់ទូលំទូលាយ។ យុវជនដែលបញ្ចប់ការសិក្សាកម្រិតឧត្តមសិក្សា បានទទួលការអប់រំលើផ្នែកទ្រឹស្តី ប៉ុន្តែភាគច្រើនខ្វះការអនុវត្តជាក់ស្តែង ខណៈដែលការងារក្នុងវិស័យទេសចរណ៍ ទាមទារទាំងចំណេះដឹង ជំនាញ និងអត្តចរិក។ ការងារក្នុងវិស័យទេសចរណ៍មានការប្រែប្រួលតាមរដូវកាល (Seasonality) ដែលជាហេតុធ្វើឲ្យម្ចាស់

អាជីវកម្មមួយចំនួនមិនបានយកចិត្តទុកដាក់ខ្ពស់លើការផ្តល់ការបណ្តុះបណ្តាលបន្ថែម និងរក្សាបុគ្គលិកឱ្យបានយូរអង្វែង។

កង្វះសាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ គឺជាបញ្ហាប្រឈមមួយក្នុងការបណ្តុះបណ្តាល និងផ្គត់ផ្គង់ជំនាញទេសចរណ៍ផងដែរ។ បច្ចុប្បន្ន មានតែសាលាបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ខ្នាតតូចមួយចំនួនប៉ុណ្ណោះ ដែលកំពុងបណ្តុះបណ្តាលជំនាញទេសចរណ៍បានប្រមាណ **១៧០០នាក់** ក្នុងមួយឆ្នាំ។ ជាផ្នែកមួយនៃដំណោះស្រាយ រាជរដ្ឋាភិបាលកម្ពុជាបានអនុញ្ញាតឱ្យក្រសួងទេសចរណ៍បង្កើតសាលាជាតិវិជ្ជាជីវៈទេសចរណ៍ **ចំនួន ០២** នៅរាជធានីភ្នំពេញ និងខេត្តព្រះសីហនុ ក្រោមកិច្ចសហប្រតិបត្តិការឥណទានជាមួយទីភ្នាក់ងារអភិវឌ្ឍន៍បារាំង (AFD) ដែលមានសមត្ថភាពបណ្តុះបណ្តាលកម្លាំងពលកម្មថ្មីបាន **១៣០០នាក់** ក្នុងមួយឆ្នាំ។ រាជរដ្ឋាភិបាលក៏បានទទួលជំនួយក្នុងក្របខណ្ឌ EIF (Enhanced Integration Framework) និងបានបង្កើតសាលាបណ្តុះបណ្តាលវិជ្ជាជីវៈចម្អិនម្ហូបកម្ពុជា (Academy of Culinary Arts - Cambodia) ដោយមានមូលនិធិ Shift 360 របស់ប្រទេសស្វីសជាអ្នកទទួលបន្ទុកអនុវត្តគម្រោង ហើយសាលាអាចបណ្តុះបណ្តាលចុងភៅប្រមាណ **៣០០នាក់** ក្នុងមួយឆ្នាំ ចាប់ពី**ឆ្នាំ២០១៧** តទៅ។

ម្យ៉ាងទៀត ក្រសួងទេសចរណ៍បានផ្តោតលើការពង្រឹងគុណភាពបណ្តុះបណ្តាលអ្នកជំនាញថ្មី និងអ្នកកំពុងបម្រើការតាមស្តង់ដាសមត្ថភាពអាស៊ាន។ យោងតាមការសិក្សាដើម្បីឆ្លើយតបទៅនឹងស្តង់ដាសមត្ថភាពអាស៊ាន ក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកលើអ្នកជំនាញទេសចរណ៍អាស៊ាន (ASEAN MRA TP) កម្ពុជាត្រូវធ្វើ**ការបណ្តុះបណ្តាលបន្ថែម**ដល់អ្នកជំនាញកំពុងបម្រើការងារ បច្ចុប្បន្នប្រមាណ **៦៣%** លើសមត្ថភាព**ចំនួន៦២** ត្រូវជា **១៨៦០ម៉ោង** ក្នុងផ្នែកការិយាល័យជួរមុខ ផ្នែកគេហកិច្ច ផ្នែកសេវាកម្មម្ហូបអាហារនិងភេសជ្ជៈ និងផ្នែកផលិតកម្មម្ហូបអាហារនៃសេវាកម្មសណ្ឋាគារ។ ចំណែកឯ សេវាកម្មធ្វើដំណើរដែលរួមមានទីភ្នាក់ងារទេសចរណ៍ និងការីទេសចរណ៍ ត្រូវធ្វើ**ការបណ្តុះបណ្តាលបន្ថែម**ដល់អ្នកកំពុងបម្រើការងារបច្ចុប្បន្នប្រមាណ **៤៥%** លើសមត្ថភាពចំនួន **៥១** ត្រូវជា **១៥៣០ម៉ោង**។ ការដោះស្រាយបញ្ហាប្រឈមនេះទាមទារកិច្ចសហការពីគ្រប់ភាគីពាក់ព័ន្ធ។

## ២.៣ ការអភិវឌ្ឍជំនាញទេសចរណ៍នៅកម្ពុជា

ក្រសួងទេសចរណ៍បានយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍជំនាញវិជ្ជាជីវៈទេសចរណ៍កម្ពុជា តាមរយៈការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ ២០១២-២០២០ ផែនការអភិវឌ្ឍន៍ទេសចរណ៍អាស៊ាន ២០១៦-២០២៥ គោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ២០១៥-២០២៥ និងគោលនយោបាយជាតិបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ២០១៧-២០២៥ សំដៅធ្វើយ៉ាងណាឱ្យជំនាញវិជ្ជាជីវៈទេសចរណ៍ជាជំនាញសម្រាប់ជីវិត បង្កើតមូលធនមនុស្សគ្រប់គ្រាន់សម្រាប់បំពេញតម្រូវការទីផ្សារការងារក្នុងប្រទេស និងតំបន់។

### ២.៣.១ ការអភិវឌ្ឍជំនាញទេសចរណ៍ជាតិ

ទេសចរណ៍មានលក្ខណៈជាប្រព័ន្ធ និងមានទំនាក់ទំនងផ្ទាល់ជាមួយអ្នកផ្តល់សេវាកម្ម (Inter-people Industry) ដោយបង្កើតបានការងារច្រើនប្រភេទដូចជាៈ សេវាកម្មដឹកជញ្ជូន ក្រុមហ៊ុនអាកាសចរណ៍ ទីភ្នាក់ងារទេសចរណ៍ ការីទេសចរណ៍ សេវាកម្មស្នាក់នៅ សេវាកម្មកំសាន្ត សេវាកម្មហូបចុក មគ្គុទ្ទេសក៏ទេសចរណ៍ ម៉ាស្សា-ស្ប៉ា និងរមណីយដ្ឋានទេសចរណ៍ជាដើម។ កន្លងមក ក្រសួងទេសចរណ៍បានយកចិត្តទុកដាក់អភិវឌ្ឍ

សមត្ថភាពអ្នកជំនាញទេសចរណ៍ដោយបានបណ្តុះបណ្តាលគ្រូបង្គោល អ្នកវាយតម្លៃបង្គោល និងអ្នកបម្រើសេវាកម្មតាមជំនាញនីមួយៗ។

ដោយមានការយកចិត្តទុកដាក់លើការផ្តល់សេវាកម្មប្រកបដោយភាពពេញចិត្តជូនភ្ញៀវទេសចរ និងជំរុញការផ្សព្វផ្សាយយុទ្ធនាការ **"កម្ពុជាៈ ព្រះរាជាណាចក្រអច្ឆរិយៈ ផ្តល់ភាពកក់ក្តៅ"** ក្រសួងទេសចរណ៍ដែលមានគណៈកម្មការចម្រុះទទួលបន្ទុកការជ្រើសរើស ការប្រឡងចូល ការគ្រប់គ្រងការបង្រៀន និងការប្រឡងចេញមគ្គុទ្ទេសក៏ទេសចរណ៍ជាសេនាធិការ បានធ្វើការបណ្តុះបណ្តាល និងពង្រឹងសមត្ថភាព មគ្គុទ្ទេសក៏ទេសចរណ៍កម្ពុជាប្រមាណជិត **៦ពាន់នាក់** ដែលមានតួនាទីអត្ថាធិប្បាយពន្យល់អំពីភូមិសាស្ត្រ ធម្មជាតិ ប្រវត្តិសាស្ត្រ វប្បធម៌ ប្រពៃណី សិល្បៈ ទំនៀម ទំលាប់ និងសេដ្ឋកិច្ចសង្គមនៅតាមទីតាំងភូមិសាស្ត្រ ដែលខ្លួនទទួលបានអាជ្ញាបណ្ណទេសចរណ៍ក្នុងការបំពេញមុខងារជាមគ្គុទ្ទេសក៏ទេសចរណ៍។ ដើម្បីធ្វើការបណ្តុះបណ្តាលប្រកបដោយគុណភាព និងប្រសិទ្ធភាព ក្រសួងទេសចរណ៍បានដាក់ចុះនូវប្រកាសស្តីពី ការប្រើប្រាស់ស្តង់ដាសមត្ថភាពមគ្គុទ្ទេសក៏ទេសចរណ៍កម្ពុជា ចាប់ពីឆ្នាំ២០១៤។

ជាមួយគ្នានេះដែរ ក្រសួងទេសចរណ៍បានបង្កើតក្រុមការងារទទួលបន្ទុកបណ្តុះបណ្តាលជំនាញម៉ាស្សា ដោយមានការសហការជាមួយគ្រប់ភាគីពាក់ព័ន្ធដើម្បីរៀបចំស្តង់ដាសមត្ថភាព និងកម្មវិធីសិក្សាបណ្តុះបណ្តាលជំនាញម៉ាស្សា រៀបចំបណ្តុះបណ្តាលគ្រូបង្គោល រៀបចំផែនការអភិវឌ្ឍជំនាញម៉ាស្សា និងការតម្រង់ទិសពេលអនាគត ព្រមទាំងរៀបចំវគ្គបណ្តុះបណ្តាល និងវគ្គវិក្រឹតការផ្សេងៗ ដើម្បីអភិវឌ្ឍជំនាញវិជ្ជាជីវៈម៉ាស្សាឲ្យមានស្តង់ដាជាក់លាក់ សម្រាប់ជាមូលដ្ឋាននៃការបណ្តុះបណ្តាល និងវាយតម្លៃផ្តល់វិញ្ញាបនបត្រ ឬសញ្ញាបត្របច្ចេកទេសស្របតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា។

ក្រសួងទេសចរណ៍ក៏បានធ្វើការបណ្តុះបណ្តាល និងកសាងសមត្ថភាពអ្នកជំនាញទេសចរណ៍កម្ពុជាលើផ្នែកបដិសណ្ឋារកិច្ច សុវត្ថិភាពចំណីអាហារ សមភាពយេនឌ័រ ការការពារកុមារ និងគ្រឿងញៀន ដល់មន្ត្រីអន្តោប្រវេសន៍ ម្ចាស់អាជីវកម្ម អ្នកលក់ដូរ និងបុគ្គលិកបម្រើការងារតាមមូលដ្ឋានអាជីវកម្មទេសចរណ៍ចំនួន **២,៥៨១រូប** អំឡុងឆ្នាំ ២០១៤-២០១៥។

ដើម្បីអភិវឌ្ឍ និងពង្រឹងប្រព័ន្ធគុណភាពអប់រំបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍កម្ពុជាឲ្យត្រូវទៅនឹងតម្រូវការនៃការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ក្រសួងទេសចរណ៍បានដាក់ចុះនូវប្រកាសស្តីពីការគ្រប់គ្រងនិងទទួលស្គាល់សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ សំដៅជំរុញឲ្យមានការទទួលស្គាល់ គុណភាពបណ្តុះបណ្តាលនិងកម្រិតគុណវុឌ្ឍិជាក់លាក់របស់អ្នកជំនាញទេសចរណ៍ និងលើកទឹកចិត្តឲ្យមានការវិនិយោគ លើការអប់រំបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍កាន់តែច្រើនឡើង។ ជាក់ស្តែងរហូតមកដល់បច្ចុប្បន្ន ក្រសួងទេសចរណ៍បានទទួលស្គាល់កម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ស្តង់ដាអាស៊ានចំនួន **១៧** រួចមកហើយ ដែលសាលាទាំងនេះមានហេដ្ឋារចនាសម្ព័ន្ធទន់និងរឹងគ្រប់គ្រាប់សម្រាប់ធ្វើការបណ្តុះបណ្តាលអ្នកជំនាញទេសចរណ៍ប្រកបដោយប្រសិទ្ធភាព និងគុណភាពខ្ពស់ស្របតាមស្តង់ដាជាតិ និងអន្តរជាតិ។

### ២.៣.១ ការអភិវឌ្ឍជំនាញទេសចរណ៍អាស៊ាន

ក្នុងបរិបទសហគមន៍សេដ្ឋកិច្ចអាស៊ាន (ASEAN Economic Community-AEC) ក្រសួងទេសចរណ៍កម្ពុជាបានយកចិត្តទុកដាក់ដល់ការបណ្តុះបណ្តាលធនធានមនុស្ស ពិសេសកំលាំងពលកម្មជំនាញ (Skilled Labor) ដែលជាតម្រូវការចាំបាច់ក្នុងសេវាកម្មទេសចរណ៍ ដើម្បីត្រៀមខ្លួនធ្វើសមាហរណកម្មតំបន់ ស្របតាមកម្មវិធីនៃកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកលើអ្នកជំនាញទេសចរណ៍អាស៊ាន (ASEAN Mutual Recognition

Arrangement On Tourism Professionals) ដែលបានចុះហត្ថលេខានៅខែមករា ឆ្នាំ២០០៩ នៅទីក្រុងហាណូយ ប្រទេសវៀតណាម ដោយរដ្ឋមន្ត្រីទេសចរណ៍អាស៊ាន នាឱកាសវេទិការទេសចរណ៍អាស៊ាន (ATF 2009)។

ការអនុវត្តកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកលើអ្នកជំនាញទេសចរណ៍អាស៊ាន (ASEAN MRA-TP) នឹងចូលរួមដល់**ការពង្រឹងគុណភាពសេវាកម្មតាមរយៈការបណ្តុះបណ្តាលធនធានមនុស្ស ឲ្យទទួលបានគុណវុឌ្ឍិស្របតាមស្តង់ដារអាស៊ានដែលធ្វើឲ្យកម្ពុជាក្លាយជាគោលដៅប្រកបដោយគុណភាព និងផ្តល់ភាពកក់ក្តៅដល់ភ្ញៀវទេសចរ។** កិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកលើអ្នកជំនាញទេសចរណ៍អាស៊ាន មានគោលដៅសម្រួលឲ្យមានការបម្លាស់ទីអ្នកជំនាញទេសចរណ៍អាស៊ាន និងការផ្លាស់ប្តូរបទពិសោធន៍រវាងប្រទេសជាសមាជិកលើការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យទេសចរណ៍ ក្នុងផ្នែកសេវាកម្មសណ្ឋាគារ និងសេវាកម្មធ្វើដំណើរលើមុខជំនាញចំនួន៣២ តាមរយៈការអនុវត្តស្តង់ដាសមត្ថភាព ស្តង់ដាបណ្តុះបណ្តាល និងយន្តការ ឬឧបករណ៍ទ្រទ្រង់រួមរបស់អាស៊ាន។ កិច្ចព្រមព្រៀងនេះ មិនត្រឹមតែផ្តល់ឱកាសការងារក្នុងតំបន់ដល់យុវជនកម្ពុជាប៉ុណ្ណោះទេ ថែមទាំងចូលរួមជំរុញការអភិវឌ្ឍជំនាញទេសចរណ៍ និងកាត់បន្ថយគម្លាតសមត្ថភាពអ្នកជំនាញក្នុងប្រទេសជាសមាជិក។ ដើម្បីសម្រេចគោលដៅនៃកិច្ចព្រមព្រៀងនេះ លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍ ដែលមានទីតាំងនៅក្រសួងទេសចរណ៍បានខិតខំរៀបចំស្តង់ដាជាតិ ក្របខ័ណ្ឌគតិយុត្ត យន្តការទ្រង់ទ្រង់ និងបំពេញភារៈកិច្ចផ្សេងៗទៀត ដោយសហការជាមួយលេខាធិការដ្ឋានអាស៊ាននៅទីក្រុងយ៉ាកាតា ប្រទេសឥណ្ឌូនេស៊ី អង្គការជាតិ អន្តរជាតិ ផ្នែកឯកជន និងភាគីពាក់ព័ន្ធផ្សេងៗទៀត។

កន្លងមកគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍ បានសម្រេចនូវលទ្ធផលធំៗមួយចំនួន ដូចជាបានបង្កើតស្តង់ដាសមត្ថភាពអ្នកជំនាញទេសចរណ៍កម្ពុជា ផ្នែកសេវាកម្មសណ្ឋាគារ និងសេវាកម្មធ្វើដំណើរ បណ្តុះបណ្តាលគ្រូបង្គោល និងអ្នកវាយតម្លៃបង្គោលអាស៊ាន ចំនួន**៣០នាក់** និងបានបណ្តុះបណ្តាល គ្រូបង្គោល និងអ្នកវាយតម្លៃបង្គោលជាតិ ប្រមាណ**៥៨២នាក់** បានរៀបចំបទដ្ឋានគតិយុត្ត យន្តការ និងដំណើរការនៃការគ្រប់គ្រងគុណភាពនៃការបណ្តុះបណ្តាល និងវាយតម្លៃ បានដាក់ឲ្យអនុវត្តកម្មវិធីបណ្តុះបណ្តាលអាស៊ានប្រកបដោយជោគជ័យនៅតាមសាលាបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍**ចំនួន ១៧** មកដល់ពេលបច្ចុប្បន្ន ហើយសាកលវិទ្យាល័យមួយចំនួនក៏កំពុងបញ្ចូលកម្មវិធីបណ្តុះបណ្តាលអាស៊ាននេះទៅក្នុងកម្មវិធីសិក្សារបស់ខ្លួនផងដែរ។ លើសពីនេះទៅទៀត ក្នុងស្មារតីនៃការអនុវត្តកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកលើអ្នកជំនាញទេសចរណ៍អាស៊ាន កម្ពុជាមានមោទនភាព ដែលយុវជនកម្ពុជាចំនួន **០៥រូប បានទទួលពានរង្វាន់មេដាយឆ្នើមផ្នែកចុងភៅ** និង**សេវាកម្ម ភោជនីយដ្ឋាន** ក្នុងការប្រកួតជំនាញអាស៊ាន **ឆ្នាំ២០១២ ២០១៤ និង២០១៦** ។

## ផ្នែកទី ៣ ÷
## ទិសដៅយុទ្ធសាស្ត្រ ២០១៧-២០២៥

ទិសដៅយុទ្ធសាស្ត្រខាងក្រោមត្រូវបានរៀបចំដើម្បីសម្រេចចក្ខុវិស័យ គោលបំណង និងគោលដៅនៃ**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យទេសចរណ៍ ២០១៧២០២៥** ។

### ៣.១ ទិសដៅយុទ្ធសាស្ត្រទី ១៖ បន្តពង្រឹងការអនុវត្តកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកលើអ្នកជំនាញទេសចរណ៍អាស៊ាន

ដើម្បីបន្តពង្រឹងការអនុវត្តកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកលើអ្នកជំនាញទេសចរណ៍ (MRA-TP) ក្រសួងទេសចរណ៍ និងគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍បានដាក់ចុះនូវសកម្មភាព យុទ្ធសាស្ត្រសំខាន់ៗ សំដៅធានាការបណ្តុះបណ្តាល និងវាយតម្លៃស្របតាមស្តង់ដាសមត្ថភាពរួមអាស៊ាន ហើយអ្នកជំនាញទទួលបានកម្រិតគុណវុឌ្ឍិជាក់លាក់ ដែលអាចចូលរួមបម្លាស់ទីការងារ ស្របតាមស្មារតីនៃកិច្ចព្រមព្រៀង MRA។

#### ៣.១.១.សកម្មភាពយុទ្ធសាស្ត្រទី ១៖ បណ្តុះបណ្តាល និងពង្រឹងសមត្ថភាពអ្នកជំនាញទេសចរណ៍ស្របតាមស្តង់ដាជាតិ និងអាស៊ាន

ការបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ស្របតាមស្តង់ជាតិ និងអាស៊ាន នឹងផ្តល់នូវគុណវុឌ្ឍិច្បាស់លាស់ដល់សិស្ស-និស្សិតដើម្បីអភិវឌ្ឍសមត្ថភាពរបស់ខ្លួន និងចាប់យកឱកាសការងារប្រកបដោយឧត្តមភាពប្រកួតប្រជែងខ្ពស់ក្នុងទីផ្សារការងារក្នុងប្រទេស និងតំបន់។ ដើម្បីជំរុញការបណ្តុះបណ្តាលអ្នកជំនាញទេសចរណ៍ឆ្ពោះទៅរកការទទួលស្គាល់ស្របតាមគុណវុឌ្ឍិជាតិ និងអាស៊ាន ក្រសួងទេសចរណ៍បានយកចិត្តទុកដាក់ជំរុញឲ្យគ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ និងកម្មវិធីបណ្តុះបណ្តាលរបស់អង្គការជាតិ និងអន្តរជាតិឲ្យមានសមត្ថភាពគ្រប់គ្រាន់ក្នុងការផ្តល់ការបណ្តុះបណ្តាលដោយពិនិត្យ និងវាយតម្លៃទាំងហេដ្ឋារចនាសម្ព័ន្ធទន់ និងរឹង។ បទដ្ឋានគតិយុទ្ធនានា និងយន្តការគ្រប់គ្រងគុណភាព គឺជាឧបករណ៍ដ៏ចាំបាច់ក្នុងការជំរុញ តាមដាន និងវាយតម្លៃការអនុវត្តស្តង់ដាជាតិ និងអាស៊ានរបស់សាលាបណ្តុះបណ្តាល និងកម្មវិធីបណ្តុះបណ្តាល ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់។

**សកម្មភាពការងារ៖**

១. ជំរុញការអនុវត្តស្តង់ដាបណ្តុះបណ្តាលរួមអាស៊ាន តាមគ្រឹះស្ថានបណ្តុះបណ្តាល កម្មវិធីបណ្តុះបណ្តាល និងភាគីឯកជន
២. ពង្រឹងគុណភាព និងបង្កើនចំនួនគ្រឹះស្ថានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍អាស៊ាន
៣. បង្កើនបរិមាណ និងគុណភាពគ្រូឲ្យមានចំណេះដឹង ជំនាញ និងបទពិសោធន៍គ្រប់គ្រាន់
៤. បន្តជំរុញការអនុវត្តកម្មវិធីបណ្តុះបណ្តាលខាងក្នុង (In-House Training)
៥. ជំរុញការអនុវត្តកម្មវិធីហ្វឹកហាត់ការងារ (Apprenticeship Program)
៦. ពង្រីកវិសាលភាពការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍អាស៊ាន ទៅកម្រិតវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស
៧. បង្កើនលទ្ធភាពទទួលបានការបណ្តុះបណ្តាលស្តង់ដាអាស៊ាន ប្រកបដោយសមធម៌យេនឌ័រ
៨. រៀបចំ និងធ្វើបច្ចុប្បន្នភាពកម្មវិធីបណ្តុះបណ្តាលស្របតាមការវិវត្តន៍ថ្មីៗនៃវិស័យទេសចរណ៍
៩. រៀបចំ និងអនុវត្តយន្តការធានាគុណភាពការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍។

#### ៣.១.២. សកម្មភាពយុទ្ធសាស្ត្រទី ២៖ ជំរុញការវាយតម្លៃទទួលស្គាល់សមត្ថភាពអ្នកជំនាញទេសចរណ៍

តាមការសិក្សាស្រាវជ្រាវឆ្នាំ២០១៦ អ្នកកំពុងបម្រើការងារបច្ចុប្បន្នក្នុងវិស័យទេសចរណ៍ មានប្រមាណជាង **២០ ភាគរយ** ដែលបានឆ្លងកាត់វគ្គសិក្សាជំនាញតាមសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ ឬថ្នាក់ឧត្តមសិក្សា ឬវគ្គបណ្តុះបណ្តាលដែលផ្តល់ដោយអង្គការក្រៅរដ្ឋាភិបាលរយៈពេលខ្លីដោយភាគច្រើនពុំបានបំពេញទៅតាម

ក្របខ័ណ្ឌគុណវុឌ្ឍិជាតិ។ រីឯបុគ្គលិកមួយចំនួនទៀតបានទទួលការបណ្តុះបណ្តាលខាងក្នុងដោយអ្នកគ្រប់គ្រង ឬម្ចាស់អាជីវកម្មរបស់ខ្លួន។ វគ្គបណ្តុះបណ្តាលក្រៅសាលាគ្រាន់តែផ្តល់នូវជំនាញមូលដ្ឋាន និងចំណេះដឹងមួយចំនួនអាចបម្រើសេវា និងបំពេញការងារនៅនឹងកន្លែងធ្វើការប៉ុណ្ណោះ ដោយមិនទាន់មានការអនុវត្តស្តង់ដាកម្មវិធីដាក់ចុះដោយក្រសួងទេសចរណ៍នៅឡើយ។ កត្តាទាំងនេះ រួមផ្សំនឹងការខ្វះខាតសាលាបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ ធ្វើឱ្យអ្នកជំនាញឆ្លៀតពេលសិក្សាជំនាញផ្សេងៗទៀត និងបោះបង់ចោលជំនាញទេសចរណ៍នៅពេលណាមួយ។ ការបោះបង់ជំនាញ និងចាកចេញពីទីផ្សារការងារទេសចរណ៍ ធ្វើឱ្យមានការបាត់បង់ជំនាញ និងមូលធនមនុស្សក្នុងវិស័យទេសចរណ៍ ដែលនឹងមិនអាចធានាបាននូវឧត្តមភាពប្រកួតប្រជែង និងផលិតភាពការងាររបស់វិស័យនេះបានទេ។

**សកម្មភាពការងារ៖**

**១.** បង្កើត និងពង្រឹងសមត្ថភាពមជ្ឈមណ្ឌលវាយតម្លៃ (Assessment Centers)

**២.** រៀបចំ និងអនុវត្តយន្តការវាយតម្លៃទទួលស្គាល់គុណវុឌ្ឍអ្នកជំនាញទេសចរណ៍ជាតិ និងអាស៊ាន

**៣.** អនុវត្តការវាយតម្លៃទទួលស្គាល់ការសិក្សាពីមុនរបស់អ្នកជំនាញទេសចរណ៍ (Recognition of Prior Learning- RPL)

**៤.** រៀបចំ និងអនុវត្តយន្តការធានានិរន្តរភាពការវាយតម្លៃអ្នកជំនាញទេសចរណ៍។

### ៣.១.៣.សកម្មភាពយុទ្ធសាស្ត្រទី ៣៖ បង្កើនឱកាសការងារ និងលទ្ធភាពបម្លាស់ទីការងារ

ទីផ្សារការងារក្នុងវិស័យទេសចរណ៍មានកំណើនយ៉ាងខ្លាំង ខណៈការជ្រើសរើសបុគ្គលិកចូលបម្រើការងារមានភាពប្រកួតប្រជែងខ្ពស់ ហើយអត្រាចាកចេញពីការងារមានកម្រិតខ្ពស់ ។ នៅពេលដែលប្រតិបត្តិករមួយចំនួនផ្តោតសំខាន់លើការផ្តល់នូវប្រាក់ឈ្នួលខ្ពស់ ជាមួយនឹងអត្ថប្រយោជន៍បន្ថែមកាន់តែ ច្រើនដល់បុគ្គលិក ការដាក់ចុះនូវកម្មវិធីអភិវឌ្ឍខ្លួនស្របតាមមាគ៌ាជំនាញ (Career Path Development) នឹងអាចរក្សាអ្នកជំនាញទេសចរណ៍ឱ្យស្ថិតនៅក្នុងវិស័យទេសចរណ៍កាន់តែយូរ និងធានាបាននូវមូលធនមនុស្សមានសមត្ថភាពបម្រើការងារប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់។ ការអនុវត្តកម្មវិធីអភិវឌ្ឍខ្លួនស្របតាមមាគ៌ាជំនាញជំរុញឱ្យអ្នកជំនាញទេសចរណ៍ចាប់យកឱកាសអភិវឌ្ឍខ្លួនស្របតាមកម្រិតគុណវុឌ្ឍិជាតិ និងអាស៊ាន ដែលផ្តល់លទ្ធភាពឱ្យអ្នកជំនាញឈានទៅចាប់ឱកាសការងារកម្រិតតំបន់ ស្របតាមស្មារតីនៃការអនុវត្តកិច្ចព្រមព្រៀង MRA។ ក្នុងន័យនេះ កន្លងមកក្រសួងទេសចរណ៍បានដាក់ចុះឱ្យមានចលនា "**បុគ្គលិកម្នាក់ ជំនាញមួយ**" ដើម្បីលើកកម្ពស់អាជីពការងារក្នុវិស័យទេសចរណ៍ ក៏ដូចជាបំផុសចលនាឱ្យយុវជនចាប់យកឱកាសការងារក្នុងវិស័យទេសចរណ៍ផងដែរ ព្រមទាំងបង្កើតឱ្យមានសេវាកម្មព័ត៌មានការងារនៅតាមមន្ទីរទេសចរណ៍រាជធានី -ខេត្តគោលដៅទេសចរណ៍ ។

**សកម្មភាពការងារ៖**

**១.** បង្កើតប្រព័ន្ធចុះបញ្ជីអ្នកជំនាញទេសចរណ៍កម្ពុជា

**២.** អនុវត្តការប្រើប្រាស់សៀវភៅជំនាញទេសចរណ៍ (Tourism Skills Passport)

**៣.** ផ្សព្វផ្សាយព័ត៌មានទីផ្សារការងារក្នុង និងក្រៅប្រទេស និងជំរុញការបម្លាស់ទីការងារ

## ៣.២ ទិសដៅយុទ្ធសាស្ត្រទី ២៖ អភិវឌ្ឍ និងពង្រឹងជំនាញវិជ្ជាជីវៈទេសចរណ៍តាមស្តង់ដាជាតិ និងតម្រូវការនៃការអភិវឌ្ឍវិស័យទេសចរណ៍កម្ពុជា

ក្រៅពីការអនុវត្តការអប់រំបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ក្នុងក្របខ័ណ្ឌ នៃការអនុវត្តកិច្ចព្រមព្រៀងMRA ក្រសួងទេសចរណ៍ បានយកចិត្តទុកដាក់លើការអប់រំបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ផ្សេងៗទៀត ដូចជាមគ្គុទ្ទេក៏ទេសចរណ៍ សេវាកម្មដឹកជញ្ជូនទេសចរណ៍ សេវាកម្មកំសាន្ត សេវាកម្មម៉ាស្សា-ស្ប៉ា សេវាកម្មរមណីយដ្ឋាន ផ្ទះសំណាក់ ភោជនីយដ្ឋាន សហគមន៍ទេសចរណ៍ជាដើម។

### ៣.២.១.រៀបចំ និងអនុវត្តស្តង់ដាបណ្តុះបណ្តាលជាតិ តាមជំនាញ

ក្រសួងទេសចរណ៍ ដោយសហការជាមួយភាគីពាក់ព័ន្ធ នឹងរៀបចំស្តង់ដាសមត្ថភាព កម្មវិធីសិក្សា និងឯកសារបណ្តុះបណ្តាលសម្រាប់ជំនាញនីមួយៗរួមមាន ជំនាញម៉ាស្សា-ស្ប៉ា មគ្គុទ្ទេសក៏ទេសចរណ៍ សេវាដឹកជញ្ជូនទេសចរណ៍ អាជីវកម្មតាមរមណីយដ្ឋាន ផ្ទះសំណាក់ មណ្ឌលកំសាន្ត និងកម្មវិធីសិក្សាសម្រាប់សិស្សវិទ្យាល័យ ដោយបន្សុីឯកសារបណ្តុះបណ្តាលជំនាញទេសចរណ៍ទៅនឹងក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា និងរៀបចំយន្តការនៃការបណ្តុះបណ្តាលបន្ត និងខាងក្នុងនៃជំនាញទេសចរណ៍ទាំងនេះ (ក្រៅពីជំនាញក្នុងក្របខ័ណ្ឌ MRA)។ ឆ្នាំ២០១៦ កន្លងទៅនេះ ក្រសួងទេសចរណ៍បានដាក់ចុះនូវស្តង់ដាបដិសណ្ឋារកិច្ច ដើម្បីជាមូលដ្ឋានក្នុងការបណ្តុះបណ្តាលដល់គ្រប់មូលដ្ឋានអាជីវកម្ម និងអ្នកផ្តល់សេវាកម្មទេសចរណ៍ទាំងអស់នៅកម្ពុជា។ ការអនុវត្តតាមស្តង់ដានេះនឹងផ្តល់លទ្ធភាពដល់សិក្ខាកាមក្នុងការសន្សំក្រេឌីត ដើម្បីស្នើសុំការវាយតម្លៃទទួលស្គាល់ថ្នាក់ជាតិ ឬអាស៊ាន។

**សកម្មភាពការងារ៖**

១. រៀបចំ និងអនុវត្តស្តង់ដាសមត្ថភាព កម្មវិធីសិក្សា ឯកសារបណ្តុះបណ្តាលជាតិតាមជំនាញ
២. រៀបចំបណ្តុះបណ្តាលគ្រូបង្គោល និងអ្នកវាយតម្លៃបង្គោលតាមជំនាញ
៣. ធ្វើការបណ្តុះបណ្តាលអ្នកជំនាញទេសចរណ៍តាមស្តង់ដាសមត្ថភាព
៤. រៀបចំ និងអនុវត្តយន្តការវាយតម្លៃអ្នកជំនាញទេសចរណ៍

### ៣.២.២. បន្តពង្រឹងចំណេះដឹង និងការយល់ដឹងសាធារណៈ អំពីវិស័យទេសចរណ៍

ទេសចរណ៍នៅតែជាវិស័យអាទិភាពចូលរួមគាំទ្រកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងនិរន្តរភាព។ ដូចនេះ ការតម្រង់ទិសយុវជន និងភាគីពាក់ព័ន្ធ ឲ្យចូលរួមការអភិវឌ្ឍវិស័យនេះ គឺជាកត្តាចាំបាច់ ដែលក្រសួងទេសចរណ៍បានយកចិត្តទុកដាក់ តាមរយៈការបញ្ជ្រាបការយល់ដឹងសាធារណៈអំពីវិស័យទេសចរណ៍កម្ពុជា និងលើកកម្ពស់ការយល់ដឹងពីបទដ្ឋានគតិយុត្តនានាទ្រទ្រង់ដល់ការអភិវឌ្ឍប្រកបដោយបរិយាប័ន្ន ជាពិសេសយកចិត្តទុកដាក់បញ្ជ្រាបការយល់ដឹងពីជំនាញទេសចរណ៍ដល់យុវជន យុវនារី នៅកម្រិតវិទ្យាល័យ។

**សកម្មភាពការងារ៖**

១. រៀបចំឯកសារ ឧបករណ៍អប់រំ និង ផ្សព្វផ្សាយជំនាញទេសចរណ៍កម្ពុជា
២. ជំរុញចលនាប្រលងប្រណាំង **"បដិសណ្ឋារកិច្ចល្អ"**
៣. បញ្ជ្រាបការយល់ដឹងសាធារណៈអំពីច្បាប់ បទដ្ឋានគតិយុត្ត ការគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ ជំនាញវិជ្ជាជីវៈទេសចរណ៍ និងផែនការអភិវឌ្ឍទេសចរណ៍នានា
៤. បន្តជំរុញការយល់ដឹងពីវិស័យទេសចរណ៍ដល់សិស្សានុសិស្សនៅកម្រិតចំណេះដឹងទូទៅ

## ៣.៣ ទិសដៅយុទ្ធសាស្ត្រទី ៣÷ ពង្រឹងសមត្ថភាពស្ថាប័ន មន្ត្រីជំនាញ និងភាពជាដៃគូរដ្ឋ-ឯកជនដើម្បីជំរុញការអប់រំបណ្តុះបណ្តាល

ការពង្រឹងសមត្ថភាពស្ថាប័ន និងមន្ត្រីជំនាញមិនត្រឹមតែចូលរួមគាំទ្រដល់កិច្ចការរៀបចំផែនការ និងគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ទាំងមូលនោះទេ ក៏ប៉ុន្តែជាសកម្មភាពដែលអាចលើកទឹកចិត្តមន្ត្រីរាជការតាមរយៈការបណ្តុះបណ្តាល និងអភិវឌ្ឍសមត្ថភាពរបស់ខ្លួនស្របតាមនិន្នាការតំបន់ និងពិភពលោក។ ម្យ៉ាងវិញទៀត ដើម្បីគាំទ្រដល់ការបណ្តុះបណ្តាលធនធានមនុស្សក្នុងវិស័យទេសចរណ៍ ទាមទារឲ្យមានការចូលរួម និងគាំទ្រពីភាគីឯកជន និងដៃគូរអភិវឌ្ឍន៍ សំដៅធានានូវការបង្កើតមូលធនមនុស្សក្នុងវិស័យទេសចរណ៍តាមរយៈកិច្ចសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព។

### ៣.៣.១. សកម្មភាពយុទ្ធសាស្ត្រទី ៣.១៖ បណ្តុះបណ្តាល និងពង្រឹងសមត្ថភាពស្ថាប័ន និងមន្ត្រីជំនាញ

ដើម្បីធានាគុណភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ ក៏ដូចជាចូលរួមគាំទ្រដល់ការបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពអ្នកជំនាញទេសចរណ៍លើគ្រប់ជំនាញ ក្រសួងទេសចរណ៍បានយកចិត្តទុកដាក់ជំរុញការបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពមន្ត្រីរាជការ ដែលទទួលបន្ទុកអនុវត្តការងារផ្ទាល់ ឲ្យមានឱកាសអភិវឌ្ឍសមត្ថភាពកាន់តែល្អប្រសើរលើជំនាញរបស់ខ្លួន ដោយខិតខំបង្កើតឲ្យមានវគ្គបណ្តុះបណ្តាលរយៈពេលខ្លី និងវែងតាមតម្រូវការជាក់ស្តែងជាមួយអង្គភាពជាដៃគូរ និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀតក្នុង និងក្រៅប្រទេស ។

**សកម្មភាពការងារ៖**

១. កំណត់ជំនាញអាទិភាពសម្រាប់ការបណ្តុះបណ្តាល និងពង្រឹងសមត្ថភាព
២. រៀបចំផែនការអភិវឌ្ឍសមត្ថភាពមន្ត្រីជំនាញ
៣. ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិដើម្បីកសាងសមត្ថភាពមន្ត្រីជំនាញ
៤. ជំរុញការបណ្តុះបណ្តាលស្តីអំពីប្រសិទ្ធភាព និងគុណភាពការងារ

### ៣.៣.២. សកម្មភាពយុទ្ធសាស្ត្រទី ៣.២៖ ពង្រឹងភាពជាដៃគូរដ្ឋ-ឯកជន ដើម្បីចូលរួមអភិវឌ្ឍ និងធានានិរន្តរភាពនៃការអប់រំបណ្តុះបណ្តាល

ដើម្បីជំរុញការបណ្តុះបណ្តាលប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់ ដែលធានានិរន្តរភាពនៃការអប់រំបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ ក្រសួងទេសចរណ៍បានយកចិត្តទុកដាក់ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជាមួយដៃគូរអភិវឌ្ឍន៍ និងភាគីឯកជនក្នុងទម្រង់ដៃគូរដ្ឋ-ឯកជន (Public-Private Partnership : PPP) សំដៅធ្វើយ៉ាងណាឲ្យយុវជនកម្ពុជាមានឱកាសចាប់យកជំនាញវិជ្ជាជីវៈទេសចរណ៍ នៅតាមតំបន់គោលដៅទេសចរណ៍សំខាន់ៗ និងនៅតំបន់សក្តានុពលអេកូទេសចរណ៍ទូទាំងប្រទេស។ ក្នុងន័យនេះ ទាមទាឲ្យមានការចូលរួមរបស់ភាគីឯកជនលើគ្រប់សកម្មភាព សំដៅអាចរក្សាមូលធនមនុស្សក្នុង វិស័យទេសចរណ៍ឲ្យបានច្រើនចូលរួមចំណែកដល់ការផ្គត់ផ្គង់ជំនាញក្នុងប្រទេស និងតំបន់។

**សកម្មភាពការងារ៖**

១. រៀបចំបទដ្ឋានគតិយុត្ត ស្តីពីការអនុវត្តកាតព្វកិច្ចបណ្តុះបណ្តាល (Training Obligation)
២. បង្កើតមូលនិធិអភិវឌ្ឍជំនាញទេសចរណ៍ (Tourism Skills Development Funds)

៣. បង្កើត និងអនុវត្តកម្មវិធីឥណទានសិក្សាជំនាញទេសចរណ៍ (Study Loan for Tourism Skills)

៤. រៀបចំយន្តការគ្រប់គ្រងតម្លៃសេវាបន្ថែមដើម្បីអភិវឌ្ឍជំនាញ (Service Charge for Tourism Skills Development)

៥. ជំរុញការអនុវត្តកម្មវិធីលើកទឹកចិត្ត និងរក្សាបុគ្គលិកក្នុងវិស័យទេសចរណ៍

៦. លើកកម្ពស់សហគ្រិនភាពក្នុងវិស័យទេសចរណ៍

៧. ជំរុញការចូលរួមពីដៃគូរអភិវឌ្ឍន៍ លើការអភិវឌ្ឍសមត្ថភាព និងជំនាញ

# ផ្នែកទី ៤ ÷ ផែនការអនុវត្តសកម្មភាព

## ៤.១ ទិសដៅយុទ្ធសាស្ត្រទី១÷ បន្តពង្រឹងការអនុវត្តកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកលើអ្នកជំនាញទេសចរណ៍អាស៊ាន

### ៤.១.១ សកម្មភាពយុទ្ធសាស្ត្រទី ១.១៖ បណ្តុះបណ្តាល និងពង្រឹងសមត្ថភាពអ្នកជំនាញទេសចរណ៍ស្របតាមស្តង់ដាជាតិ និងអាស៊ាន




| អង្គភាពទទួលខុសត្រូវ | គណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍ |
|---|---|
| **សូចនាករ** | (១) ភាគីពាក់ព័ន្ធចូលរួមអនុវត្តកិច្ចព្រមព្រៀង MRA-TP យ៉ាងផុលផុស (២) បទដ្ឋានគតិយុត្តមួយចំនួនត្រូវបានរៀបចំ (៣) អ្នកជំនាញទេសចរណ៍មានការទទួលស្គាល់ និងអាចបម្លាស់ទីការងារក្នុងតំបន់ស្របតាមស្មារតីនៃកិច្ចព្រមព្រៀង MRA-TP |

## ៤.១.២ សកម្មភាពយុទ្ធសាស្ត្រទី ១.២៖ ជំរុញការវាយតម្លៃទទួលស្គាល់សមត្ថភាពអ្នកជំនាញទេសចរណ៍




| អង្គភាពទទួលខុសត្រូវ | គណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍ |
|---|---|
| **សូចនាករ** | (១) យន្តការទទួលស្គាល់មជ្ឈមណ្ឌលវាយតម្លៃត្រូវបានរៀបចំ<br>(២) អ្នកវាយតម្លៃមានបទពិសោធន៍ និងសមត្ថភាពខ្ពស់<br>(៣) យន្តការវាយតម្លៃការសិក្សាពីមុនត្រូវបានអភិវឌ្ឍ<br>(៤) អ្នកជំនាញដែលកំពុងបម្រើការងារត្រូវបានទទួលស្គាល់កម្រិតគុណវុឌ្ឍិជាក់លាក់ |

### ៤.១.៣ សកម្មភាពយុទ្ធសាស្ត្រទី ១.៣៖ បង្កើនឱកាសការងារ និងលទ្ធភាពបម្លាស់ទីការងារ




| **អង្គភាពទទួលខុសត្រូវ** | **គណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍** |
|---|---|
| **សូចនាករ** | (១) ប្រព័ន្ធចុះបញ្ជីអ្នកជំនាញទេសចរណ៍កម្ពុជាត្រូវបានបង្កើតដោយបន្សុីជាមួយប្រព័ន្ធចុះបញ្ជីអាស៊ាន<br>(២) សមត្ថភាព និងគុណវុឌ្ឍិអ្នកជំនាញទេសចរណ៍ត្រូវបានកត់ត្រាក្នុងសៀវភៅជំនាញទេសចរណ៍<br>(៣) ព័ត៌មានការងារបានដល់គ្រប់ភាគីពាក់ព័ន្ធ |

## ៤.២ ទិសដៅយុទ្ធសាស្ត្រទី២៖  អភិវឌ្ឍ និងពង្រឹងជំនាញវិជ្ជាជីវៈទេសចរណ៍តាមស្តង់ដាជាតិ និងតម្រូវការនៃការអភិវឌ្ឍវិស័យទេសចរណ៍កម្ពុជា

### ៤.២.១ សកម្មភាពយុទ្ធសាស្ត្រទី ២.១៖ រៀបចំ និងអនុវត្តស្តង់ដាបណ្តុះបណ្តាលជាតិ តាមជំនាញ




| អង្គភាពទទួលខុសត្រូវ | គណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍<br>នាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និង អង្គភាពពាក់ព័ន្ធ |
|---|---|
| សូចនាករ | (១) ស្តង់ដាសមត្ថភាព កម្មវិធីបណ្តុះបណ្តាល និងឯកសារបណ្តុះបណ្តាលជំនាញអាទិភាពត្រូវបានរៀបចំ<br>(២) គ្រូបង្គោល និងអ្នកវាយតម្លៃបង្គោលមានសមត្ថភាពខ្ពស់<br>(៣) អ្នកជំនាញដែលកំពុងបម្រើការងារទទួលបានការវាយតម្លៃ និងទទួលស្គាល់ |

### ៤.២.២ សកម្មភាពយុទ្ធសាស្ត្រទី ២.២៖ បន្តពង្រឹងចំណេះដឹង និងការយល់ដឹងសាធារណៈ អំពីវិស័យទេសចរណ៍




| អង្គភាពទទួលខុសត្រូវ | នាយកដ្ឋានជំរុញទេសចរណ៍ក្នុងស្រុក និងអប់រំការយល់ដឹងសាធារណៈ<br>នាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍<br>គ.ជ.អ.ទ. / គ.ជ.វ.ទ. |
|---|---|
| **សូចនាករ** | (១) ឯកសារផ្សព្វផ្សាយទេសចរណ៍ និងជំនាញវិជ្ជាជីវៈទេសចរណ៍ត្រូវបានរៀបចំ និងផ្សព្វផ្សាយ<br>(២) ភាគីពាក់ព័ន្ធចូលរួមចលនាប្រលងប្រណាំង **“បដិសណ្ឋាកិច្ចល្អ”** យ៉ាងផុលផុស<br>(៣) ប្រតិបត្តិករទេសចរណ៍យល់ដឹងយ៉ាងទូលំទូលាយពីកាតព្វកិច្ចអនុវត្តច្បាប់ និងបទដ្ឋានគតិយុត្តទេសចរណ៍ |

### ៤.៣ ទិសដៅយុទ្ធសាស្ត្រទី៣៖ ពង្រឹងសមត្ថភាពស្ថាប័ន មន្ត្រីជំនាញ និងភាពជាដៃគូរដ្ឋ-ឯកជនដើម្បីការអប់រំបណ្តុះបណ្តាល

### ៤.៣.១ សកម្មភាពយុទ្ធសាស្ត្រទី ៣.១៖ បណ្តុះបណ្តាល និងពង្រឹងសមត្ថភាពស្ថាប័ន និងមន្ត្រីជំនាញ




| **អង្គភាពទទួលខុសត្រូវ** | **នាយកដ្ឋានធនធានមនុស្ស**<br>**នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធ** |
|---|---|
| **សូចនាករ** | (១) មន្ត្រីរាជការត្រូវបានបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពកាន់តែល្អប្រសើរ<br>(២) មន្ត្រីរាជការបំពេញការងារប្រកបដោយប្រសិទ្ធភាពខ្ពស់ |

## ៤.៣.២ សកម្មភាពយុទ្ធសាស្ត្រទី ៣.២៖ ពង្រឹងភាពជាដៃគូរដ្ឋ-ឯកជន ដើម្បីចូលរួមអភិវឌ្ឍ និងធានានិរន្តរភាពនៃការអប់រំបណ្តុះបណ្តាល




| **អង្គភាពទទួលខុសត្រូវ** | **គណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍**<br>**នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធ** |
|---|---|
| **សូចនាករ** | (១) ប្រតិបត្តិករទេសចរណ៍ចូលរួមអនុវត្តកាតព្វកិច្ចបណ្តុះបណ្តាលប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់<br>(២) សិស្ស-និស្សិតក្រីក្រមានលទ្ធភាពចាប់សិក្សាជំនាញវិជ្ជាជីវៈទេសចរណ៍<br>(៣) អត្រាចាកចេញពីការងារក្នុងវិស័យទេសចរណ៍មានការថយចុះ<br>(៤) ភាគីឯកជន និងដៃគូរអភិវឌ្ឍន៍ចូលរួមគាំទ្រការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍យ៉ាងផុលផុស |

## ផ្នែកទី ៥ ៖

## ការតាមដានត្រួតពិនិត្យការអនុវត្ត និងការវាយតម្លៃ

ដើម្បីធានាវឌ្ឍនភាព ប្រសិទ្ធភាព និងសង្គតិភាពជាប្រចាំក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រនេះ លេខាធិការដ្ឋាន គ.ជ.អ.ទ នាយកដ្ឋានបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ត្រូវសម្របសម្រួល តាមដាន ពិនិត្យ និងវាយតម្លៃ លើការអនុវត្ត **"ផែនការយុទ្ធសាស្ត្រអភិវឌ្ឍធនធានមនុស្សក្នុងវិស័យទេសចរណ៍ ២០១៧-២០២៥"** ព្រមទាំងត្រូវរៀបចំរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំជូនថ្នាក់ដឹកនាំក្រសួងទេសចរណ៍ ដើម្បីត្រួតពិនិត្យវឌ្ឍនភាព និងបញ្ហាប្រឈមនានា ដោយផ្អែកលើទិសដៅយុទ្ធសាស្ត្រ សកម្មភាពយុទ្ធសាស្ត្រ និងសូចនាករដែលបានកំណត់ ដើម្បីជាមូលដ្ឋានសម្រាប់ធ្វើការសម្រេចចិត្តលើវិធានការបន្ទាន់ចាំបាច់ក្នុងការដោះស្រាយបញ្ហាចំពោះមុខ ដែលកើតឡើងក្នុងពេលអនុវត្តផែនការយុទ្ធសាស្ត្រនេះ ។

សម្រាប់សកម្មភាពយុទ្ធសាស្ត្រនីមួយៗ អង្គភាពទទួលបន្ទុកអនុវត្តត្រូវរៀបចំសកម្មភាពលម្អិត ដោយមានថេរវេលាជាក់លាក់។ លទ្ធផល និងឥទ្ធិពលដែលកើតចេញពីការអនុវត្តសកម្មភាពនេះត្រូវមានលក្ខណៈអាចវាស់វែងបាន ហើយផែនការអនុវត្តនីមួយៗត្រូវភ្ជាប់មកជាមួយនូវការប៉ាន់ស្មានទំហំថវិការដែលត្រូវការ។ ប្រភពថវិការសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រនេះអាចជាថវិការបស់រដ្ឋ ឬជាធនធានទទួលបានពីភាគីពាក់ព័ន្ធ និងដៃគូរអភិវឌ្ឍន៍ផ្សេងៗ។

មន្ទីរទេសចរណ៍រាជធានី-ខេត្តត្រូវរៀបចំផែនការបណ្តុះបណ្តាល ដើម្បីអភិវឌ្ឍសមត្ថភាពអ្នកជំនាញទេសចរណ៍នៅតាមបណ្តារាជធានី-ខេត្តរបស់ខ្លួន ឲ្យឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្រ ដែលបានដាក់ចុះ ដោយរៀបចំរបាយការណ៍ផ្ញើរមកក្រសួងទេសចរណ៍ ដើម្បីតាមដាន និងត្រួតពិនិត្យ។

# ផ្នែកទី ៦ ÷ សេចក្តីសន្និដ្ឋាន

ឯកសារ **"ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យទេសចរណ៍ ២០១៧-២០២៥"** គឺជាផែនទីចង្អុលបង្ហាញទិសរបស់ក្រសួងទេសចរណ៍ ដើម្បីអភិវឌ្ឍវិស័យអប់រំបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ពេញមួយជីវិត តាមរយៈការផ្តល់នូវចំណេះដឹង ជំនាញ និងអត្តចរិកដល់យុវជនកម្ពុជាសម្រាប់បំពេញការងារប្រកបដោយផលិតភាពខ្ពស់ ក្នុងទីផ្សារការងារក្នុងតំបន់ និងអន្តរជាតិ សំដៅគាំទ្រដល់ការផ្តល់សេវាកម្មប្រកដោយភាពពេញចិត្ត ស្របតាមយុទ្ធនាការផ្សព្វផ្សាយទេសចរណ៍ "**កម្ពុជា÷ព្រះរាជាណាចក្រអច្ឆរិយៈ ផ្តល់ភាពកក់ក្តៅ**"។

ផែនការយុទ្ធសាស្រ្តនេះមានចក្ខុវិស័យច្បាស់លាស់ ដោយបង្ហាញនូវទិសដៅយុទ្ធសាស្រ្តធំៗចំនួន ០៣គឺ (**ទី១**) បន្តពង្រឹងការអនុវត្តកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកលើអ្នកជំនាញទេសចរណ៍អាស៊ាន (**ទី២**) អភិវឌ្ឍ និងពង្រឹងជំនាញវិជ្ជាជីវៈទេសចរណ៍តាមស្តង់ដាជាតិ និងតម្រូវការនៃការអភិវឌ្ឍវិស័យទេសចរណ៍កម្ពុជា (**ទី៣**) ពង្រឹងសមត្ថភាពស្ថាប័ន មន្ត្រីជំនាញ និងភាពជាដៃគូរដ្ឋ-ឯកដើម្បីជំរុញការអប់រំបណ្តុះបណ្តាល។

ផ្អែកលើផែនការយុទ្ធសាស្រ្តនេះ ក្រសួងទេសចរណ៍សង្ឃឹមថាអ្នកជំនាញទេសចរណ៍ និងមន្ត្រីរាជការនៃក្រសួងទេសចរណ៍ នឹងមានសមត្ថភាពខ្ពស់ក្នុងការប្រតិបត្តិការងាររបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងគុណភាពខ្ពស់ ហើយភាគីពាក់ព័ន្ធ ដៃគូរអភិវឌ្ឍន៍ អង្គការ សមាគមទេសចរណ៍ និងគ្រឹះស្ថានអប់រំបណ្តុះបណ្តាល នឹងចូលរួមចំណែកក្នុងការជំរុញផ្សព្វផ្សាយ គាំទ្រ និងអនុវត្តផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យទេសចរណ៍នេះ ឲ្យបានជោគជ័យ ប្រកបដោយស្មារតី សហប្រតិបត្តិការ និងទទួលខុសត្រូវខ្ពស់។

# សទ្ទានុក្រម

| | |
|---|---|
| ការវាយតម្លៃ (Assessment) | ជាដំណើរការនៃការប្រមូលភស្តុតាង ដើម្បីបញ្ជាក់ថាតើអ្នកសិក្សាទទួលបានស្តង់ដាដែលតម្រូវឬទេ។ ការវាយក៏ត្រូវបានប្រើជាផ្នែកនៃដំណើរការសិក្សា ដើម្បីជួយដល់អ្នកសិក្សាក្នុងការធ្វើឲ្យមានការរីកចម្រើន (វឌ្ឍនកម្មផ្នែកចំណេះដឹង ជំនាញ និងសមត្ថភាព)។ |
| ក្រេឌីត (Credit) | ជាឯកតា ឬតម្លៃដែលយកជាខ្នាតសម្រាប់វាស់វែងពីលទ្ធផលសិក្សាសម្រេចបាននៅក្នុងសញ្ញាណម៉ោងនៃកម្រិតគុណវុឌ្ឍិដែលបានផ្តល់។ ជាតម្លៃដែលផ្តល់សម្រាប់ការសិក្សាដែលសម្រេចបាន និងត្រូវបានផ្ទៀងផ្ទាត់តាមរយៈការវាយតម្លៃត្រឹមត្រូវ និងជឿទុកចិត្តបាន។ |
| ការផ្ទេរក្រេឌីត (Credit Transfer) | ជាដំណើរការតាមក្រេឌីតដែលទទួលបាននៅក្នុងគ្រឹះស្ថាន ឬប្រព័ន្ធមួយអាចនឹងត្រូវទទួលបានស្គាល់ដោយគ្រឹះស្ថាន ឬប្រព័ន្ធមួយទៀត។ |
| កម្មវិធីសិក្សា (Curriculum) | ជាសំណុំនៃការងារនៅតាមពេលនៃការអភិវឌ្ឍកម្មវិធីសិក្សា រួមមានការកំណត់គោលដៅ ខ្លឹមសារ វិធីសាស្ត្រ (រួមទាំងការវាយតម្លៃ) និងសមត្ថភាពនៃការបណ្តុះបណ្តាល។ |
| កម្រិត (Level) | សំដៅលើទីតាំងដែលគុណវុឌ្ឍិមួយស្ថិតនៅក្នុងក្របខ័ណ្ឌគុណវុឌ្ឍិទៅតាមរយៈកម្រិតគុណវុឌ្ឍិ។ |
| ក្របខ័ណ្ឌគុណវុឌ្ឍិជាតិ (National Qualification Framework) | ជាលិខិតតូបករណ៍សម្រាប់ធ្វើការអភិវឌ្ឍ និងចំណាត់ថ្នាក់គុណវុឌ្ឍិដោយអាស្រ័យទៅនឹងកម្រងលក្ខណៈវិនិច្ឆ័យ នៃការសិក្សាដែលសម្រេចបានតាមកម្រិតនីមួយៗ ដោយកម្រងលក្ខណៈវិនិច្ឆ័យនោះបានបញ្ជាក់ជាលក្ខណៈទូទៅក្នុងការពិពណ៌នាគុណវុឌ្ឍិក្នុងកម្រិតនីមួយៗនៃក្របខ័ណ្ឌគុណវុឌ្ឍិ។ |
| គុណវុឌ្ឍិ (Qualification) | ១. ជាបណ្តុំសម្ថភាពដែលឆ្លើយតបទៅនឹងតួនាទីការងារ និងផ្នែកសំខាន់នៅកន្លែងធ្វើការ។<br>២. ជាវិញ្ញាបនបត្រ សញ្ញាបត្រ ឬកម្រិតដែលផ្តល់ឲ្យដោយគ្រឹះស្ថាន ផ្តល់ការអប់រំ ឬក្រុម ដែលមានសិទ្ធិផ្តល់គុណវុឌ្ឍិ និបញ្ជាក់ពីការទទួលបានផលសិក្សា។<br>៣.ជាការបញ្ជាក់ផ្លូវការ ដែលចេញដោយអង្គភាពពាក់ព័ន្ធ ក្នុងការទទួលស្គាល់ថាបុគ្គលម្នាក់សម្រេចបានលទ្ធផលសិក្សា ឬសមត្ថភាពដែល |

| | |
|---|---|
| | ទាក់ទងទៅនឹងតម្រូវការរបស់បុគ្គល អាជីព ក្រុមហ៊ុន ឬ សហគមន៍។ |
| ការធានាគុណភាព (Quality Assurance) | សំដៅដល់ពាក្យទូទៅសម្រាប់គ្រប់គ្រងសកម្មភាពដែលផ្តល់ការធានាថា សេវានៃការអប់រំ និងការបណ្តុះបណ្តាលរបស់គ្រឹះស្ថាន ឬអង្គភាព ត្រូវបានផ្តល់ប្រកបដោយប្រសិទ្ធភាពជាប់ជានិច្ច ទៅតាមការស្តង់ដា និងស្របតាមគោលដៅ និងគោលបំណងដែលបានផ្សព្វផ្សាយ។ |
| ការទទួលស្គាល់ការសិក្សាពីមុន (Recognition of Prior Learning) | សំដៅដល់ការទទួលស្គាល់ និងផ្តល់សុពលភាពលើសមត្ថភាព សម្រាប់គោលបំណងនៃការធ្វើវិញ្ញាបនកម្ម (ការបញ្ជាក់) ដែលបានពីក្រៅប្រព័ន្ធអប់រំ និងបណ្តុះបណ្តាល។ |
| ការចុះបញ្ជី (Registration) | ជាដំណើរការផ្តល់ឲ្យគ្រឹះស្ថានមួយនូវឱកាស ដើម្បីបង្កើតទំនាក់ទំនងដែលមានការទទួលស្គាល់ជាផ្លូវការ និងជាសាធារណៈជាមួយស្ថាប័នជាតិពាក់ព័ន្ធ (អាជ្ញាធរមានសមត្ថកិច្ច)។ |
| ជំនាញ (Skills) | ជាសមត្ថភាពប្រើប្រាស់ចំណេះដឹង ដើម្បីបំពេញការងារ និងដោះស្រាយបញ្ហា។ ជំនាញត្រូវបានពិពណ៌នាជាចំណេះដឹងវិភាគ (ការប្រើគំនិតប្រកបដោយភាពត្រឹមត្រូវ អព្ភន្តរញាណ និងការច្នៃប្រឌិត) និងការអនុវត្ត (ទាក់ទងនឹងទេពកោសល្យហត្ថកម្ម ឬជំនាញប្រើដោយដៃនិងការប្រើវិធិសាស្ត្រ សម្ភារៈ ឧបករណ៍ និងគ្រឿងប្រដាប់ផ្សេងៗ។ |
| សមត្ថភាព (Competency) | គឺជាចំណេះដឹង ជំនាញ និងឥរិយាបថជាក់លាក់ដែលត្រូវក្នុងកន្លែងការងារ ហើយអនុវត្តនូវចំណេះដឹង និងជំនាញទាំងនោះ ប្រតិបត្តិសកម្មភាពការងារឲ្យឆ្លើយតបទៅនឹងស្តង់ដាប្រតិបត្តិដែលបានកំណត់។ |
| ការវាយតម្លៃសមត្ថភាព (Competency Assessment) | ជាដំណើរការនៃការប្រមូលភស្តុតាង និងធ្វើការវាយតម្លៃ នៅក្នុងការវិនិច្ឆ័យលើសមត្ថភាពដែលទទួលបានជោគជ័យ។ |
| បរិយាប័ន្ន Inclusiveness | លក្ខណៈរួមបញ្ចូលគ្រប់ភាគីពាក់ព័ន្ធ ឬលក្ខណៈប្រកបដោយសមធម៌ |

# ឧបសម្ព័ន្ធទី១

## ឧបសម្ព័ន្ធទី១៖ តារាងផែនការសកម្មភាពលម្អិត និងសូចនាករនៃភាពជោគជ័យ

*ទិសដៅយុទ្ធសាស្ត្រទី១៖ បន្តពង្រឹងការអនុវត្តកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកលើអ្នកជំនាញទេសចរណ៍អាស៊ាន*

*សកម្មភាពយុទ្ធសាស្ត្រ ១.១៖ បណ្តុះបណ្តាល និងពង្រឹងសមត្ថភាពអ្នកជំនាញទេសចរណ៍ ស្របតាមស្តង់ដាជាតិ និងអាស៊ាន នៃសេវាកម្មសណ្ឋាគារ និងសេវាកម្មធ្វើដំណើរ*

| សកម្មភាពលម្អិត | សូចនាករនៃភាពជោគជ័យ |
|---|---|
| **១.១.១** ជំរុញការអនុវត្តស្តង់ដាបណ្តុះបណ្តាលរួមអាស៊ាន តាមគ្រឹះស្ថានបណ្តុះបណ្តាល កម្មវិធីបណ្តុះបណ្តាល និងភាគីឯកជន | ▪ ការដាក់ឲ្យប្រើប្រាស់ជាផ្លូវការ<br>▪ បានផ្សព្វផ្សាយដល់ភាគីពាក់ព័ន្ធ |
| **១.១.២** ពង្រឹងគុណភាព និងបង្កើនចំនួនគ្រឹះស្ថានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍អាស៊ាន | ▪ ចំនួនគ្រឹះស្ថានបណ្តុះបណ្តាលដែលបានអនុវត្ត<br>▪ ចំនួនសិក្ខាកាមបញ្ចប់ការសិក្សា និងមានសមត្ថភាព |
| **១.១.៣** បង្កើនបរិមាណ និងគុណភាពគ្រូឲ្យមានចំណេះដឹង ជំនាញ និងបទពិសោធន៍គ្រប់គ្រាន់ | ▪ ចំនួនគ្រូបង្គោល និងអ្នកវាយតម្លៃអាស៊ាន<br>▪ ចំនួនគ្រូនិងអ្នកវាយតម្លៃបង្គោលជាតិ |
| **១.១.៤** បន្តជំរុញការអនុវត្តកម្មវិធីបណ្តុះបណ្តាលខាងក្នុង (In-House Training) | ▪ ចំនួនអង្គភាពអាជីវកម្មដែលបានអនុវត្ត<br>▪ ចំនួនសិក្ខាកាមទទួលការបណ្តុះបណ្តាល |
| **១.១.៥** ជំរុញការអនុវត្តកម្មវិធីហ្វឹកហាត់ការងារ (Apprenticeship Program) | ▪ ចំនួនប្រតិបត្តិករចូលរួម<br>▪ ចំនួនសិក្ខាកាម |
| **១.១.៦** ពង្រីកវិសាលភាពការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍អាស៊ាន ទៅកម្រិត វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស | ▪ ចំនួនសាលា និង សិស្សដែលបានអនុវត្ត |

| | |
|---|---|
| **១.១.៧** បង្កើនលទ្ធភាពទទួលបានការបណ្តុះបណ្តាលស្តង់ដាអាស៊ាន ប្រកបដោយសមធម៌យេនឌ័រ | ▪ ចំនួនសិក្ខាកាម ប្រកបដោយសមធម៌យេនឌ័រ |
| **១.១.៨** រៀបចំ និងធ្វើបច្ចុប្បន្នភាពកម្មវិធីបណ្តុះបណ្តាលស្របតាមការវិវត្តន៍ថ្មីៗនៃវិស័យទេសចរណ៍ | ▪ ផ្សព្វផ្សាយខ្លឹមសារថ្មីៗ |
| **១.១.៩** រៀបចំ និងអនុវត្តយន្តការធានាគុណភាពការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ | ▪ បានដាក់យន្តការឲ្យប្រើប្រាស់<br>▪ បានផ្សព្វផ្សាយដល់ភាគីពាក់ព័ន្ធ |

**<u>សកម្មភាពយុទ្ធសាស្ត្រ ១.២</u>៖ ជំរុញការវាយតម្លៃទទួលស្គាល់សមត្ថភាពអ្នកជំនាញទេសចរណ៍**

| **សកម្មភាពលម្អិត** | **សូចនាករនៃភាពជោគជ័យ** |
|---|---|
| **១.២.១** បង្កើត និងពង្រឹងសមត្ថភាពមជ្ឈមណ្ឌលវាយតម្លៃ (Assessment Centers) | ▪ ចំនួនមជ្ឈមណ្ឌល វាយតម្លៃ ការអនុវត្ត |
| **១.២.២** រៀបចំ និងអនុវត្តយន្តការវាយតម្លៃទទួលស្គាល់គុណវុឌ្ឍអ្នកជំនាញទេសចរណ៍ជាតិ និងអាស៊ាន | ▪ ផ្សព្វផ្សាយយន្តការ<br>▪ ដាក់ឲ្យប្រើប្រាស់ជាផ្លូវការ |
| **១.២.៣** អនុវត្តការវាយតម្លៃទទួលស្គាល់ការសិក្សាពីមុនរបស់អ្នកជំនាញទេសចរណ៍ (Recognition of Prior Learning- RPL) | ▪ ចំនួនអ្នកជំនាញបានវាយតម្លៃ |
| **១.២.៤** រៀបចំ និងអនុវត្តយន្តការធានានិរន្តរភាពការវាយតម្លៃអ្នកជំនាញទេសចរណ៍ | ▪ ផ្សព្វផ្សាយយន្តការ<br>▪ ដាក់ឲ្យប្រើប្រាស់ជាផ្លូវការ |

***សកម្មភាពយុទ្ធសាស្ត្រ ១.៣៖ បង្កើនឱកាសការងារ និងលទ្ធភាពបម្លាស់ទីការងារ***

| សកម្មភាពលម្អិត | សូចនាករនៃភាពជោគជ័យ |
|---|---|
| ១.៣.១ បង្កើតប្រព័ន្ធចុះបញ្ជីអ្នកជំនាញទេសចរណ៍កម្ពុជា | ▪ ចំនួនអ្នកជំនាញកម្ពុជាបានចុះបញ្ជី |
| ១.៣.២ អនុវត្តការប្រើប្រាស់សៀវភៅជំនាញទេសចរណ៍ (Tourism Skills Passport) | ▪ ចំនួនអ្នកជំនាញប្រើប្រាស់សៀវភៅជំនាញ |
| ១.៣.៣ ផ្សព្វផ្សាយព័ត៌មានទីផ្សារការងារក្នុង និងក្រៅប្រទេស និងជំរុញការបម្លាស់ទី | ▪ ចំនួនព័ត៌មានដែលបានផ្សព្វផ្សាយ<br>▪ ចំនួនអ្នកមើល |

***ទិសដៅយុទ្ធសាស្ត្រទី២៖ អភិវឌ្ឍ និងពង្រឹងជំនាញវិជ្ជាជីវៈទេសចរណ៍តាមស្តង់ដាជាតិ និងតម្រូវការនៃការអភិវឌ្ឍវិស័យ ទេសចរណ៍កម្ពុជា***

***សកម្មភាពយុទ្ធសាស្ត្រ ២.១៖ រៀបចំ និងអនុវត្តស្តង់ដាបណ្តុះបណ្តាលជាតិ តាមជំនាញ***

| សកម្មភាពលម្អិត | សូចនាករនៃភាពជោគជ័យ |
|---|---|
| ២.១.១ រៀបចំ និងអនុវត្តស្តង់ដាសមត្ថភាព កម្មវិធីសិក្សា ឯកសារបណ្តុះបណ្តាលជាតិតាមជំនាញ | ▪ ការដាក់ឲ្យប្រើប្រាស់ជាផ្លូវការ<br>▪ បានផ្សព្វផ្សាយដល់ភាគីពាក់ព័ន្ធ |
| ២.១.២ រៀបចំបណ្តុះបណ្តាលគ្រូបង្គោល និងអ្នកវាយតម្លៃបង្គោលតាមជំនាញ | ▪ ចំនួនគ្រូបង្គោល និងអ្នកវាយតម្លៃ |
| ២.១.៣ ធ្វើការបណ្តុះបណ្តាល អ្នកជំនាញទេសចរណ៍តាមស្តង់ដាសមត្ថភាព | ▪ ចំនួនអ្នកជំនាញដែលបានបណ្តុះបណ្តាល |
| ២.១.៤ រៀបចំ និងអនុវត្តយន្តការវាយតម្លៃ អ្នកជំនាញទេសចរណ៍ | ▪ ឯកសារយន្តការត្រូវបានដាក់ឲ្យអនុវត្ត<br>▪ បានផ្សព្វផ្សាយដល់ភាគីពាក់ព័ន្ធ |

***សកម្មភាពយុទ្ធសាស្ត្រទី ២.២៖** បន្តពង្រឹងចំណេះដឹង និងការយល់ដឹងសាធារណៈ អំពីវិស័យទេសចរណ៍*

| សកម្មភាពលម្អិត | សូចនាករនៃភាពជោគជ័យ |
|---|---|
| **២.២.១** រៀបចំឯកសារ ឧបករណ៍អប់រំ និង ផ្សព្វផ្សាយជំនាញទេសចរណ៍កម្ពុជា | ▪ ទទួលការគាំទ្រពីផ្នែកឯកជន សាលាបណ្តុះបណ្តាល និងអង្គភាពពាក់ព័ន្ធ<br>▪ ផ្សព្វផ្សាយខ្លឹមសារតាមតំបន់គោលដៅទេសចរណ៍សំខាន់ៗ |
| **២.២.២** ជំរុញចលនាប្រលងប្រណាំង “**បដិសណ្ឋារកិច្ចល្អ**” | ▪ ផ្សព្វផ្សាយចលនាប្រលងប្រណាំង<br>▪ ចំនួនប្រតិបត្តិករទេសចរណ៍ចូលរួម |
| **២.២.៣** បញ្ជ្រាបការយល់ដឹងសាធារណៈអំពីច្បាប់ បទដ្ឋានគតិយុត្ត ការគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ ជំនាញវិជ្ជាជីវៈទេសចរណ៍ និងផែនការអភិវឌ្ឍទេសចរណ៍នានា | ▪ ចំនួនប្រតិបត្តិករចូលរួម<br>▪ ចំនួនសិក្ខាកាម |
| **២.២.៤** បន្តជំរុញការយល់ដឹងពីវិស័យទេសចរណ៍ដល់សិស្សានុសិស្សនៅកម្រិតចំណេះដឹងទូទៅ | ▪ ចំនួនគ្រូផ្នែកទ្រឹស្តី និងអនុវត្ត<br>▪ ការអនុវត្តតួនាទីភារកិច្ចរបស់គ្រូ |

*ទិសដៅយុទ្ធសាស្ត្រទី៣៖ ពង្រឹងសមត្ថភាពស្ថាប័ន មន្ត្រីជំនាញ និងភាពជាដៃគូរដ្ឋ-ឯកជនតាមរយៈការអប់រំបណ្តុះបណ្តាល*

***សកម្មភាពយុទ្ធសាស្ត្រ ៣.១** ទាក់ទាញ លើកទឹកចិត្ត និងរក្សាអ្នកជំនាញក្នុងវិស័យទេសចរណ៍កម្ពុជា*

| សកម្មភាពលម្អិត | សូចនាករ |
|---|---|
| **៣.១.១** កំណត់ជំនាញអាទិភាពសម្រាប់ការបណ្តុះបណ្តាល និងពង្រឹងសមត្ថភាព | ▪ រកឃើញកត្តាដែលមានឥទ្ធិពលលើសេចក្តីពេញចិត្តរបស់អ្នកបម្រើការងារ |

| | |
|---|---|
| | ▪ ការផ្តល់នូវដំណោះស្រាយ និងសកម្មភាពត្រូវធ្វើ<br>▪ ផ្សព្វផ្សាយលទ្ធផលសិក្សា |
| **៣.១.២** រៀបចំផែនការអភិវឌ្ឍសមត្ថភាពមន្ត្រីជំនាញ | ▪ បានផ្សព្វផ្សាយដល់ភាគីពាក់ព័ន្ធ<br>▪ មន្ត្រីជំនាញមានការយល់ដឹងថ្មីៗ |
| **៣.១.៣** ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិដើម្បីកសាងសមត្ថភាពមន្ត្រីជំនាញ | ▪ ចំនួនដៃគូសហការ<br>▪ ចំនួនមន្ត្រីជំនាញចូលរួម |
| **៣.១.៤** ជំរុញការបណ្តុះបណ្តាលស្តីអំពីប្រសិទ្ធភាព និងគុណភាពការងារ | ▪ ចំនួនសិក្ខាកាមចូលរួម |

<u>**សកម្មភាពយុទ្ធសាស្ត្រទី ៣.២៖**</u> ***ពង្រឹងភាពជាដៃគូរវាង-ឯកជន ដើម្បីចូលរួមអភិវឌ្ឍ និងធានានិរន្តរភាពនៃការអប់រំបណ្តុះបណ្តាល***

| **សកម្មភាពលម្អិត** | **សូចនាករ** |
|---|---|
| **៣.២.១** រៀបចំបទដ្ឋានគតិយុត្តស្តីពីការអនុវត្តកាតព្វកិច្ចបណ្តុះបណ្តាល | ▪ ផ្សព្វផ្សាយយន្តការ<br>▪ ដាក់ឲ្យប្រើប្រាស់ជាផ្លូវការ |
| **៣.២.២** បង្កើតមូលនិធិអភិវឌ្ឍជំនាញទេសចរណ៍ (Tourism Skills Development Funds) | ▪ មូលនិធិត្រូវបានបង្កើត<br>▪ ចំនួនអង្គភាពដែលស្នើសុំមូលនិធិមានការកើនឡើង |
| **៣.២.៣ បង្កើត និងអនុវត្តកម្មវិធីឥណទាន សិក្សាជំនាញទេសចរណ៍** (Study Loan for Tourism Skills) | ▪ **កម្មវិធីឥណទាន**ត្រូវបានបង្កើត<br>▪ ចំនួនអង្គភាពចូលរួម |

| | |
|---|---|
| **៣.២.៤ រៀបចំយន្តការគ្រប់គ្រងតម្លៃសេវាបន្ថែមដើម្បីអភិវឌ្ឍជំនាញ** (Service Charge for Tourism Skills Development) | ▪ ផ្សព្វផ្សាយយន្តការ<br>▪ ដាក់ឲ្យប្រើប្រាស់ជាផ្លូវការ |
| **៣.២.៥ ជំរុញការអនុវត្តកម្មវិធីលើកទឹកចិត្ត និងរក្សាបុគ្គលិកក្នុងវិស័យទេសចរណ៍** | ▪ ចំនួនអង្គភាពចូលរួម |
| **៣.២.៦ លើកកម្ពស់សហគ្រិនភាពក្នុងវិស័យទេសចរណ៍** | ▪ ចំនួនអង្គភាពចូលរួម |
| **៣.២.៧ ជំរុញការចូលរួមពីដៃគូរអភិវឌ្ឍន៍ លើការអភិវឌ្ឍសមត្ថភាព និងជំនាញ** | ▪ ចំនួនដៃគូសហការ |

# ឧបសម្ព័ន្ធទី២

**ឧបសម្ព័ន្ធទី២៖** តារាងសង្ខេបផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជំនាញទេសចរណ៍អាស៊ាន ២០១៦-២០២៥

"By 2025, ASEAN will be a quality tourism destination offering a unique, diverse ASEAN experience, and will be committed to responsible, sustainable, inclusive and balanced tourism development, so as to contribute significantly to the socio-economic well-being of ASEAN people"

| Strategic Directions | **SD 1**<br>Enhance competitiveness of ASEAN as a single tourism destination | **SD 2**<br>Ensure that ASEAN tourism is sustainable and inclusive |
|---|---|---|
| Strategic Action Programs | 1.1 Intensify Promotion and Marketing | 2.1 Upgrade Local Communities and Public- Private Sector Participation in the Tourism Value Chain |
| | 1.2 Diversify Tourism Product | 2.2 Ensure Safety and Security, Prioritize Protection and Management of Heritage Sites |
| | 1.3 Attract Tourism Investments | 2.3 Increase Responsiveness to Environmental Protection and Climate Change |
| | 1.4 Raise Capacity and Capability of Human Capital | |
| | 1.5 Implement and Expand ASEAN Tourism Standards for Facilities, Services and Destinations | |
| | 1.6 Implement and Expand Connectivity and Destination Infrastructure | |
| | 1.7 Enhance Travel Facilitation | |

# ឧបសម្ព័ន្ធទី៣

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...០៩...អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១០

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើតគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍ ដែលសរសេរកាត់ថា **គ.ជ.អ.ទ.** ដើម្បីសម្រួលការធ្វើបម្លាស់ទីអ្នកជំនាញទេសចរណ៍ ក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងជំរុញការផ្លាស់ប្តូរ ការអនុវត្តល្អៗ ក្នុងការកសាងសមត្ថភាពអ្នកជំនាញទេសចរណ៍ នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងនៅក្នុងប្រទេសជាសមាជិកអាស៊ានដទៃទៀត។

## ជំពូកទី២
## សមាសភាព

**មាត្រា ២.-**

សមាសភាព **គ.ជ.អ.ធ.** មានដូចខាងក្រោម៖

| | | |
|---|---|---|
| ១. រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | | ប្រធាន |
| ២. រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ០១ រូប | អនុប្រធាន |
| ៣. រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | ០១ រូប | សមាជិក |
| ៤. រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ០១ រូប | សមាជិក |
| ៥. រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ០១ រូប | សមាជិក |
| ៦. រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ០១ រូប | សមាជិក |
| ៧. តំណាងក្រសួងមហាផ្ទៃផ្នែកនគរបាលជាតិ | ០១ រូប | សមាជិក |
| ៨. តំណាងគណៈកម្មាធិការជាតិបណ្តុះបណ្តាល | ០១ រូប | សមាជិក |
| ៩. តំណាងគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា | ០១ រូប | សមាជិក |
| ១០. តំណាងសមាគមឧស្សាហកម្មទេសចរណ៍ | មួយចំនួន | សមាជិក |
| ១១. តំណាងគ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ | មួយចំនួន | សមាជិក។ |

សមាសភាពជាក់ស្តែងរបស់ **គ.ជ.អ.ធ.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៣
## តួនាទី និងភារកិច្ច

**មាត្រា ៣.-**

**គ.ជ.អ.ធ.** មានតួនាទីនិងភារកិច្ចដូចខាងក្រោម ៖

-បញ្ជ្រាបការយល់ដឹង និងការផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងកិច្ចព្រមព្រៀងទទួលស្គាល់គ្នា ទៅវិញទៅមក នៃអ្នកជំនាញទេសចរណ៍អាស៊ាន ព្រមទាំងផ្សព្វផ្សាយដំណឹង អំពីការងារលើប្រព័ន្ធចុះបញ្ជីអ្នកជំនាញទេសចរណ៍អាស៊ាន

-ពិនិត្យ តាមដាន និងធ្វើបច្ចុប្បន្នភាពលើស្តង់ដារសមត្ថភាព ស្តង់ដារជំនាញ កម្មវិធីបណ្តុះបណ្តាលរួមនិងនិយាមផ្សេងៗទៀត ដែលត្រូវយកទៅប្រើប្រាស់ជាមូលដ្ឋាន សម្រាប់ការបណ្តុះបណ្តាល និងសម្រាប់ការវាយតម្លៃលើគុណវុឌ្ឍិ សមត្ថភាពអ្នកជំនាញទេសចរណ៍អាស៊ាន តាមមុខជំនាញទេសចរណ៍ ដែលត្រូវបានទទួលស្គាល់ជារួមក្នុងក្របខ័ណ្ឌអាស៊ាន ដែលជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ

-វាយតម្លៃលើគុណវុឌ្ឍិ និងសមត្ថភាពអ្នកជំនាញទេសចរណ៍ ដូចបានកំណត់ក្នុងស្តង់ដារសមត្ថភាពរួមរបស់អាស៊ាន សម្រាប់អ្នកជំនាញទេសចរណ៍ កម្មវិធីសិក្សារួមរបស់អាស៊ាន សម្រាប់អ្នកជំនាញទេសចរណ៍

-ពិនិត្យនិងតាមដានការប្រតិបត្តិរបស់អ្នកជំនាញទេសចរណ៍ ក្រោយពេលទទួលបានវិញ្ញាបនបត្របញ្ជាក់សមត្ថភាពវិជ្ជាជីវៈទេសចរណ៍ ពីគណៈកម្មាធិការជាតិបណ្តុះបណ្តាល

-សម្រួលការផ្លាស់ប្តូរព័ត៌មានទាក់ទងនឹងនីតិវិធីវាយតម្លៃ លក្ខណវិនិច្ឆ័យ និងប្រព័ន្ធផ្សព្វផ្សាយកិច្ចព្រម-ព្រៀងទទួលស្គាល់គ្នាទៅវិញទៅមក នៃអ្នកជំនាញទេសចរណ៍អាស៊ាន

-ជូនដំណឹងដល់គណៈកម្មាធិការត្រួតពិនិត្យ អ្នកជំនាញទេសចរណ៍របស់អាស៊ាន ក្នុងករណីដែលអ្នកជំនាញទេសចរណ៍អាស៊ាន ដែលប្រកបអាជីពក្នុងព្រះរាជាណាចក្រកម្ពុជា លែងមានគុណវុឌ្ឍិក្នុងការផ្តល់សេវារបស់ខ្លួន ឬក្នុងករណីដែលអ្នកជំនាញទេសចរណ៍ បានរំលោភលើស្តង់ដារបច្ចេកទេសវិជ្ជាជីវៈ ឬក្រមសីលធម៌វិជ្ជាជីវៈ

-លើកសំណើជូនគណៈកម្មាធិការជាតិបណ្តុះបណ្តាល ដើម្បីដកហូតវិញ្ញាបនបត្រទទួលស្គាល់ ពីអ្នកជំនាញទេសចរណ៍ណាដែលលែងមានគុណវុឌ្ឍិ ក្នុងការផ្តល់សេវារបស់ខ្លួន ឬពីអ្នកជំនាញទេសចរណ៍ណាដែលរំលោភស្តង់ដារបច្ចេកទេសវិជ្ជាជីវៈ ឬក្រមសីលធម៌វិជ្ជាជីវៈ

-រៀបចំ និងពង្រឹងប្រសិទ្ធភាពការងារ ព្រមទាំងយន្តការសំខាន់ៗ ដើម្បីសម្រួលការអនុវត្តកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមក នៃអ្នកជំនាញទេសចរណ៍អាស៊ាន

-ធ្វើសហការជាមួយក្រសួង ស្ថាប័ន ផ្នែកឯកជន និងភាគីពាក់ព័ន្ធទាំងអស់ ដើម្បីសម្របសម្រួលការងារខាងលើ ឲ្យមានប្រសិទ្ធភាព

-បំពេញការងារផ្សេងៗទៀតតាមការប្រគល់ជូនរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៤
## ការប្រព្រឹត្តទៅរបស់ គ.ជ.អ.ទ.

**មាត្រា ៤.-**

**គ.ជ.អ.ទ.** បើកកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធាន។

**មាត្រា ៥.-**

**គ.ជ.អ.ទ.** អាចអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ មន្ត្រីជំនាញ អ្នកឯកទេស ឬផ្នែកឯកជន ឲ្យចូលរួមប្រជុំពិគ្រោះ ពិភាក្សា ផ្តល់យោបល់ និងសិក្សាស្រាវជ្រាវលើរាល់បញ្ហាទាំងឡាយ ដែលពាក់ព័ន្ធនឹងក្របខ័ណ្ឌការងាររបស់ខ្លួន។

**មាត្រា ៦.-**

បែបបទនិងនីតិវិធីអនុវត្តការងាររបស់ **គ.ជ.អ.ទ.** ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់ **គ.ជ.អ.ទ.**។

**មាត្រា ៧.-**

**គ.ជ.អ.ទ.** អាចបង្កើតក្រុមការងារជំនាញមួយចំនួនតាមការចាំបាច់ ដើម្បីជានាប្រសិទ្ធភាពនៃកិច្ចដំណើរការរបស់ខ្លួន។ តួនាទី និងភារកិច្ចក្រុមការងារជំនាញនីមួយៗ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ជ.អ.ទ.**។

**មាត្រា ៨.-**

**គ.ជ.អ.ទ.** អាចទទួលយកទីប្រឹក្សាបច្ចេកទេស អ្នកជំនាញការជាតិ ឬអន្តរជាតិនានាមួយចំនួន តាមការចាំបាច់។

**មាត្រា ៩.-**

**គ.ជ.អ.ទ.** មានលេខាធិការដ្ឋានមួយនៅក្រសួងទេសចរណ៍ ជាសេនាធិការ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន **គ.ជ.អ.ទ.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ដែលជាប្រធាន **គ.ជ.អ.ទ.**។

**មាត្រា ១០.-**

**គ.ជ.អ.ទ.** មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងទេសចរណ៍ ក្នុងកិច្ចដំណើរការងារប្រចាំថ្ងៃរបស់ខ្លួន។

## ជំពូកទី៥
## ប្រភពធនធាន

**មាត្រា ១១.-**

**គ.ជ.អ.ឆ.** មានប្រភពធនធានផ្គត់ផ្គង់ដោយកញ្ចប់ថវិកាមួយដោយឡែក ដែលជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួងទេសចរណ៍ និងមូលនិធិដែលបានមកពីប្រភពហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍ ព្រមទាំងប្រភពស្របច្បាប់ផ្សេងៗទៀត សម្រាប់បំពេញការងាររបស់ខ្លួនឲ្យមានប្រសិទ្ធភាព។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា ១២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល ៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ២០១១
## ស្ដីពី
## ការបង្កើតគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍

១. មុខជំនាញទេសចរណ៍សម្រាប់ធ្វើការវាយតម្លៃក្នុងព្រះរាជាណាចក្រកម្ពុជា និងប្រទេសសមាជិកអាស៊ានដទៃទៀត មានជាអាទិ៍៖

១. ចំពោះសេវាកម្មសណ្ឋាគារ ( Hotel Services )

ក. ផ្នែកការិយាល័យខាងមុខ ( Front Office )
- អ្នកគ្រប់គ្រងការិយាល័យខាងមុខ ( Front Office Manager)
- អ្នកចាត់ការការិយាល័យខាងមុខ ( Front Office Supervisor )
- បុគ្គលិកទទួលភ្ញៀវ ( Receptionist )
- បុគ្គលិកទទួលទូរស័ព្ទ ( Telephone Operator )
- អ្នកជញ្ជូនឥវ៉ាន់ភ្ញៀវ ( Bell Boy )

ខ. ផ្នែកគេហកិច្ច ( House Keeping )
- អ្នកគ្រប់គ្រងផ្នែកគេហកិច្ច ( Executive Housekeeper )
- អ្នកគ្រប់គ្រងផ្នែកបោកអ៊ុត ( Laundry Manager )
- អ្នកចាត់ការសម្អាតតាមជាន់ ( Floor Supervisor )
- បុគ្គលិកបោកអ៊ុត ( Laundry Attendant )
- បុគ្គលិកសម្អាតបន្ទប់ ( Room Attendant )
- បុគ្គលិកសម្អាតទីសាធារណៈ ( Public Area Cleaner )

គ. ផ្នែកផលិតកម្មម្ហូបអាហារ ( Food Production )
- មេចុងភៅគ្រប់គ្រងលើការចម្អិនអាហារ (Executive Chef )
- មេចុងភៅចម្អិនអាហារតាមផ្នែក ( Demi Chef )
- ជំនួយការចុងភៅចម្អិនអាហារតាមផ្នែក ( Commis Chef )
- ចុងភៅទទួលខុសត្រូវតាមផ្នែក (Chef de Partie )
- ជំនួយការផ្នែកធ្វើបង្អែម ( Commis Pastry )
- អ្នកដុតនំ ( Baker )
- បុគ្គលិកហាន់សាច់ ( Butcher )

ឃ. ផ្នែកសេវាកម្មអាហារ និងភេសជ្ជៈ ( Food and Beverage Service )
- នាយកគ្រប់គ្រងផ្នែកអាហារនិងភេសជ្ជៈ ( F&B Director )
- អ្នកចាត់ការកន្លែងលក់អាហារនិងភេសជ្ជៈ ( F&B Outlet Manager )
- អ្នកគ្រប់គ្រងបុគ្គលិកផ្នែកបម្រើ ( Head Waiter )
- បុគ្គលិកផ្នែកលាយភេសជ្ជៈ ( Bartender )
- បុគ្គលិកផ្នែកបម្រើ ( Waiter )

២. ចំពោះសេវាកម្មការធ្វើដំណើរ (Travel Services )

ក. ផ្នែកភ្នាក់ងារទេសចរណ៍ ( Travel Agencies )

- នាយកគ្រប់គ្រង ( General Manager )
- ជំនួយការនាយកគ្រប់គ្រង ( Assistant General Manager )
- ទីប្រឹក្សាជាន់ខ្ពស់ផ្នែកការធ្វើដំណើរ ( Senior Travel Consultant )
- ទីប្រឹក្សាផ្នែកការធ្វើដំណើរ ( Travel Consultant)

ខ. ផ្នែកប្រតិបត្តិការខ្សែទេសចរណ៍ ( Tour Operation )

- អ្នកគ្រប់គ្រងផ្នែកផលិត (Product Manager )
- អ្នកគ្រប់គ្រងផ្នែកលក់ និងទីផ្សារ ( Sales and Marketing Manager )
- អ្នកគ្រប់គ្រងផ្នែកឥណទាន ( Credit Manager )
- អ្នកគ្រប់គ្រងផ្នែកលក់សំបុត្រ ( Ticketing Manager )
- អ្នកគ្រប់គ្រងផ្នែកខ្សែទេសចរណ៍ ( Tour Manager )

មុខជំនាញទេសចរណ៍សម្រាប់ធ្វើការវាយតម្លៃខាងលើអាចត្រូវបានកែប្រែតាមការសម្រេចរបស់ប្រទេសសមាជិកអាស៊ាន នាពេលអនាគត។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិ**

លេខ: ០០១ ប្រក.គជអទ

# ប្រកាស
# ស្តីពី
# ការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃ
# គណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍
## និងជាប្រធានគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍
- យោងតាមសំណូមពរចាំបាច់នៃការងាររបស់គណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍

## ស ម្រេ ច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះកំណត់ពីបេសកកម្ម តួនាទី ភារកិច្ច ការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍ "**គ.ជ.អ.ទ.**"។

-១

## ជំពូកទី២
## បេសកកម្ម តួនាទី និងភារកិច្ច

**ប្រការ ២.-**

លេខាធិការដ្ឋាននៃ **គ.ជ.អ.ទ.** ជាសេនាធិការឱ្យ **គ.ជ.អ.ទ.** ក្នុងការអនុវត្តការងារ ដូចខាងក្រោម៖

១. លើកសំណើក្នុងការរៀបចំ និងកែលម្អស្តង់ដារសមត្ថភាព និងកម្មវិធីសិក្សារួមសម្រាប់អ្នកជំនាញទេសចរណ៍អាស៊ាន

២. តាមដាន និងវាយតម្លៃការអនុវត្តវិជ្ជាជីវៈរបស់អ្នកជំនាញទេសចរណ៍អាស៊ាន

៣. ធ្វើការសិក្សាអំពីដំណើរការអភិវឌ្ឍន៍ និងតម្រូវការការងារក្នុងជំនាញវិជ្ជាជីវៈទេសចរណ៍របស់អាស៊ាន

៤. សម្របសម្រួលការងារនានារបស់ **គ.ជ.អ.ទ.** ជាមួយស្ថាប័នជាតិ អន្តរជាតិ និងបុគ្គលពាក់ព័ន្ធ ដើម្បីធានាដំណើរការការងាររបស់ **គ.ជ.អ.ទ.** ឱ្យកាន់តែមានប្រសិទ្ធភាព

៥. កសាងកញ្ចប់ថវិកាមួយដោយឡែក ដែលជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួងទេសចរណ៍ ដើម្បីធានានិរន្តរភាពនៃកិច្ចសហប្រតិបត្តិការ និងសម្រាប់បំពេញមុខងាររបស់ខ្លួនឱ្យមានប្រសិទ្ធភាព

៦. រៀបចំកិច្ចប្រជុំនានារបស់ **គ.ជ.អ.ទ.**

៧. ធ្វើរបាយការណ៍ជាប្រចាំពីវឌ្ឍនភាពនានានៃកិច្ចដំណើរការរបស់ **គ.ជ.អ.ទ.** និងរបាយការណ៍ផ្សេងទៀតតាមការកំណត់របស់ប្រធាន **គ.ជ.អ.ទ.**

៨. អនុវត្តរាល់ផែនការសកម្មភាពដែល **គ.ជ.អ.ទ** បានដាក់ចេញ

៩. បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់ប្រធាន **គ.ជ.អ.ទ.**។

## ជំពូកទី៣
## រចនាសម្ព័ន្ធ

**ប្រការ ៣.-**

លេខាធិការដ្ឋានរបស់ **គ.ជ.អ.ទ.** ជាអង្គភាពប្រតិបត្តិរបស់ **គ.ជ.អ.ទ.** ដែលដឹកនាំដោយ ប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់។

**ប្រការ ៤.-**

លេខាធិការដ្ឋានរបស់ **គ.ជ.អ.ទ.** បែងចែកជា **០៣** ផ្នែកគឺ៖

១- ផ្នែកស្តង់ដារ និងវាយតម្លៃ

២- ផ្នែកផែនការ នីតិកម្ម សហប្រតិបត្តិការ និងព័ត៌មាន

៣- ផ្នែករដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ

ផ្នែកនីមួយៗដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួន តាមការចាំបាច់។

ផ្នែកនីមួយៗត្រូវមានក្រុមការងារចំណុះមួយចំនួន តាមការចាំបាច់។ តួនាទី និងភារកិច្ចរបស់ក្រុមការងារ និងការបង្កើត ឬការលុបចោល ត្រូវសម្រេចដោយប្រធានរបស់ **គ.ជ.អ.ទ.**។

**ប្រការ ៥.-**

**ផ្នែកស្តង់ដារ និងវាយតម្លៃ មានភារកិច្ចដូចតទៅ៖**

- រៀបចំ និងកែលម្អស្តង់ដារសមត្ថភាព និងកម្មវិធីសិក្សារួមរបស់អ្នកជំនាញទេសចរណ៍អាស៊ាន
- រៀបចំ និងកែលម្អនីតិវិធីវិនិច្ឆ័យសមត្ថភាពរបស់អ្នកជំនាញទេសចរណ៍អាស៊ាន
- វាយតម្លៃគុណវុឌ្ឍិ សមត្ថភាព អ្នកជំនាញ
- តាមដាន និងវាយតម្លៃគុណភាពការងារតាមជំនាញនីមួយៗរបស់អ្នកជំនាញទេសចរណ៍
- រៀបចំ និងកែលម្អគោលការណ៍ណែនាំសម្រាប់អ្នកជំនាញទេសចរណ៍ ដើម្បីទទួលបានគុណភាពតាមស្តង់ដារមូលដ្ឋានដែលបានកំណត់
- បញ្ជូនឯកសារវាយតម្លៃអ្នកជំនាញទេសចរណ៍ទៅកាន់អនុគណៈកម្មការជាតិទទួលស្គាល់អ្នកជំនាញទេសចរណ៍ ដើម្បីសម្រេច និងផ្តល់វិញ្ញាបនបត្រ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាព និងលទ្ធផលការងាររបស់ខ្លួនតាមកាលកំណត់
- ជ្រើសរើសគ្រូបង្គោល និងអ្នកវាយតម្លៃអ្នកជំនាញទេសចរណ៍
- តាមដាន និងវាយតម្លៃសាលាបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ ឱ្យស្របតាមកម្មវិធីសិក្សារួមសម្រាប់អ្នកជំនាញទេសចរណ៍អាស៊ាន។
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់ប្រធានលេខាធិការដ្ឋាន។

**ប្រការ ៦.-**

**ផ្នែកផែនការ នីតិកម្ម សហប្រតិបត្តិការ និងព័ត៌មាន មានភារកិច្ចដូចតទៅ:**

- រៀបចំផែនការសកម្មភាពការងាររបស់ **គ.ជ.អ.ទ.**
- ចូលរួមរៀបចំផែនការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍
- ធ្វើទំនាក់ទំនង សម្របសម្រួល និងសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ន ផ្នែកឯកជន អង្គការជាតិ អន្តរជាតិ និងប្រទេសជាសមាជិកអាស៊ានដោយសហការជាមួយផ្នែកជំនាញ
- រៀបចំបទដ្ឋានគតិយុត្តនានា។ អនុស្សរណៈ កិច្ចព្រមព្រៀង ឬគម្រោងសហប្រតិបត្តិការទ្វេភាគី និងពហុភាគីជាមួយស្ថាប័នជាតិ និងអន្តរជាតិនានា
- បង្កើត រចនា អភិវឌ្ឍ និងធ្វើបច្ចុប្បន្នភាពព័ត៌មានលើគេហទំព័ររបស់ **គ.ជ.អ.ទ.**
- សម្រួលការផ្លាស់ប្តូរព័ត៌មានតាមគ្រប់មធ្យោបាយលើកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកនៃអ្នកជំនាញទេសចរណ៍អាស៊ាន
- ធ្វើការផ្សព្វផ្សាយ និងផ្តល់សេវាព័ត៌មានទីផ្សារការងារដល់អ្នកជំនាញទេសចរណ៍ជាតិ និងអាស៊ាន
- ធ្វើរបាយការណ៍ស្តីពីសកម្មភាព និងលទ្ធផលការងាររបស់ខ្លួនតាមកាលកំណត់ និង
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់ប្រធានលេខាធិការដ្ឋាន។

**ប្រការ ៧.-**

**ផ្នែករដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ មានភារកិច្ចដូចតទៅ:**

សហការជាមួយនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ នាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាលធនធានមនុស្ស នៃក្រសួងទេសចរណ៍ដើម្បី:

- ធានាប្រសិទ្ធភាព និងនិរន្តរភាពនៃដំណើរការការងាររដ្ឋបាលរបស់លេខាធិការដ្ឋាន
- ទទួលខុសត្រូវលើការងាររដ្ឋបាលទូទៅ ពិធីការ រៀបចំពិធី និងសិក្ខាសាលាផ្សេងៗ

- រៀបចំគម្រោងចំណូល-ចំណាយថវិកាប្រចាំឆ្នាំ
- គ្រប់គ្រងអចលនទ្រព្យ ចលនទ្រព្យ និងបញ្ជីសារពើភណ្ឌ
- ផ្គត់ផ្គង់សម្ភារៈ បរិក្ខារ និងការចំណាយផ្សេងៗ សម្រាប់ដំណើរការរបស់លេខាធិការដ្ឋាន
- រៀបចំគោលនយោបាយ គ្រប់គ្រង និងជ្រើសរើសបុគ្គលិក
- រៀបចំតារាងប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភនានាដល់មន្ត្រីនៃ **គ.ជ.អ.ឆ.**
- លើកសំណើតាមនីតិវិធី ដើម្បីសុំការសម្រេចលើគម្រោងចំណាយផ្សេងៗ
- ធ្វើការទំនាក់ទំនងជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និង អង្គការនានា ដើម្បីស្វែងរកជំនួយថវិកាឧបត្ថមបន្ថែម
- រក្សាទុកឯកសារពាក់ព័ន្ធនឹងការវាយតម្លៃលើគុណវុឌ្ឍិ និងសមត្ថភាពអ្នកជំនាញទេសចរណ៍
- ធ្វើរបាយការណ៍ស្តីពីសកម្មភាព និងលទ្ធផលការងាររបស់ខ្លួនតាមកាលកំណត់ និង
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់ប្រធានលេខាធិការដ្ឋាន។

**ប្រការ ៨.-**

ប្រធាន អនុប្រធានលេខាធិការដ្ឋាន និងប្រធានផ្នែកនៃលេខាធិការដ្ឋាន **គ.ជ.អ.ឆ.** ត្រូវទទួលបានឋានន្តរស័ក្តិ និងប្រាក់បំណាច់មុខការស្របតាមមុខដំណែង និងឋានៈនីមួយៗរបស់ខ្លួន។

**ប្រការ ៩.-**

មន្ត្រីរាជការបំរើការងារនៅក្នុងលេខាធិការដ្ឋានរបស់ **គ.ជ.អ.ឆ.** ត្រូវបានជ្រើសរើសចេញពីមន្ត្រីរាជការដែលស្ថិតក្នុងក្របខ័ណ្ឌមុខងារសាធារណៈនៅក្រសួងទេសចរណ៍។

ការរៀបចំឋានន្តរស័ក្តិ ប្រាក់បៀវត្សមូលដ្ឋាន ប្រាក់បំណាច់មុខងារ និងប្រាក់បន្ទាប់បន្សំ នៃបៀវត្សរបស់មន្ត្រីរាជការទាំងអស់ នៃលេខាធិការដ្ឋានរបស់ **គ.ជ.អ.ឆ.** ជាបន្ទុករបស់ក្រសួងទេសចរណ៍។

**ប្រការ ១០.-**

លេខាធិការដ្ឋានរបស់ **គ.ជ.អ.ឆ.** អាចជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យាតាមការចាំបាច់។ ប្រាក់បំណាច់ ឬប្រាក់ឈ្នួលរបស់បុគ្គលិកជាប់កិច្ចសន្យា ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ជ.អ.ឆ.** ។

## ជំពូកទី៤
## ថវិកា

**ប្រការ ១១.-**

លេខាធិការដ្ឋានប្រើប្រាស់ថវិការបស់ **គ.ជ.អ.ឆ.** ដែលជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួងទេសចរណ៍ និងដែលបានមកពីប្រភពស្របច្បាប់ផ្សេងៗទៀតសម្រាប់ដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**ប្រការ ១២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ១៣.-**

សមាជិក សមាជិកានៃគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍ ប្រធាន អនុប្រធានលេខាធិការដ្ឋាន ប្រធាន អនុប្រធានផ្នែក និងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១១

**គណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍**

**ប្រធាន**

**ថោង ខុន**

**រដ្ឋមន្ត្រីក្រសួងទេសចរណ៍**

***កន្លែងទទួល :***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ដូចប្រការ១៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

-៥

# ឧបសម្ព័ន្ធទី ៤

# ASEAN MUTUAL RECOGNITION ARRANGEMENT ON TOURISM PROFESSIONALS

## PREAMBLE

The Governments of Brunei Darussalam, the Kingdom of Cambodia, the Republic of Indonesia, the Lao People's Democratic Republic, Malaysia, the Union of Myanmar, the Republic of the Philippines, the Republic of Singapore, the Kingdom of Thailand, and the Socialist Republic of Viet Nam, Member States of the Association of South East Asian Nations (hereinafter collectively referred to as "ASEAN" or "ASEAN Member States" and singularly as "ASEAN Member State");

**RECOGNISING** the objectives of the ASEAN Framework Agreement on Services (hereinafter referred to as "AFAS"), which are to enhance cooperation in services amongst ASEAN Member States in order to improve efficiency and competitiveness, diversify production capacity and supply and distribution of services of their services suppliers within and outside ASEAN; to eliminate substantially the restrictions to trade in services amongst ASEAN Member States; and to liberalise trade in services by expanding the depth and scope of liberalisation beyond those undertaken by ASEAN Member States under the General Agreement on Trade in Services (hereinafter referred to as "GATS") with the aim to realising free trade in services;

**RECOGNISING** the ASEAN Vision 2020 on Partnership in Dynamic Development, approved on 14 June 1997, which charted towards the year 2020 for the creation of a stable, prosperous and highly competitive ASEAN Economic Region which would result in:

- free flow of goods, services and investment;

- equitable economic development, and reduced poverty and socio-economic disparities; and
- enhanced political, economic and social stability;

**RECOGNISING** the objectives of the ASEAN Tourism Agreement (hereinafter referred to as "ATA"), which are to cooperate in facilitating travel into and within ASEAN; to enhance cooperation in the tourism industry among ASEAN Member States in order to improve its efficiency and competitiveness; to substantially reduce restrictions to trade in tourism and travel services among ASEAN Member States; to enhance the development and promotion of ASEAN as a single tourism destination with world-class standards, facilities and attractions; to enhance mutual assistance in human resource development and strengthen cooperation to develop, upgrade and expand tourism and travel facilities and services in ASEAN; and to create favourable conditions for the public and private sectors to engage more deeply in tourism development, intra-ASEAN travel and investment in tourism services and facilities;

**RECOGNISING** the Cebu Declaration on the Establishment of the ASEAN Community by 2015 adopted at the $12^{th}$ ASEAN Summit that agreed to accelerate the establishment of an ASEAN Community by 2015 along the lines of ASEAN Vision 2020 and the Declaration of ASEAN Concord II in the three pillars of the ASEAN Security Community, ASEAN Economic Community and ASEAN Socio-Cultural Community;

**NOTING** the decision of the Bali Concord II adopted at the Ninth ASEAN Summit held in 2003 in Bali, Indonesia calling for completion of Mutual Recognition Arrangements for qualifications in major professional services by 2008; and

**NOTING** that the ASEAN Framework for the Integration of Priority Sectors (2004) recognizes the priority for the creation of a single economic area for ASEAN and the importance of close partnerships with the private sector,

**HAVE AGREED** on this ASEAN Mutual Recognition Arrangement on Tourism Professionals (hereinafter referred to as "this Arrangement") as follows:

## ARTICLE I
## OBJECTIVES

The objectives of this Arrangement are:

1.1 To facilitate mobility of Tourism Professionals; and

1.2 To exchange information on best practices in competency-based education and training for Tourism Professionals and to provide opportunities for cooperation and capacity building across ASEAN Member States.

## ARTICLE II
## DEFINITIONS AND SCOPE

In this Arrangement, unless the context otherwise states,

2.1 **ASEAN Common Competency Standards for Tourism Professionals (ACCSTP)** refers to the minimum requirements of competency standards in hotel and travel services as listed in the APPENDIX which aim to upgrade tourism services and facilitate the development of this Arrangement between ASEAN Member States;

2.2 **ASEAN National Tourism Organizations (ASEAN NTOs)** refers to the government institutions in charge of the tourism sector of ASEAN Member States;

2.3 **ASEAN Tourism Professional Monitoring Committee (ATPMC)** consists of ASEAN NTOs and appointed representatives from the National Tourism Professional Boards (NTPBs);

2.4 **ASEAN Tourism Professional Registration System (ATPRS)** refers to a web-based facility to disseminate details regarding the list of Foreign Tourism Professionals duly certified in accordance with Articles 2.10 and 2.14;

2.5 **Assessment** refers to the process of appraising the qualification and/or competencies of Tourism Professionals;

2.6 **Certification** refers to the issuance of a certificate to Tourism Professional whose qualification and/or competencies have met the standards specified in ACCSTP;

2.7 **Common ASEAN Tourism Curriculum (CATC)** refers to the common curriculum for ASEAN Tourism Professionals as mutually agreed upon by the ASEAN Tourism Ministers upon recommendation by the ASEAN NTOs;

2.8 **Foreign Tourism Professionals** refer to Tourism Professionals who are nationals of any other ASEAN Member States who are certified in an ASEAN Member State;

2.9 **Host Country** refers to the ASEAN Member State where a Foreign Tourism Professional applies for recognition to work in accordance with ARTICLE III;

2.10 **National Tourism Professional Board (NTPB)** refers to the Board for Tourism Professionals which shall be composed of representatives from the public and private sectors including the academia and other relevant tourism stakeholders, to be determined by the respective ASEAN NTOs;

2.11 **Recognition** refers to acceptance by the TPCB of a demonstration of compliance with requirements set out in the ACCSTP;

2.12 **Tourism Job Title** refers to a specific job position in the tourism sector as specified in the ACCSTP;

2.13 **Tourism Professional** refers to a natural person who holds the nationality of an ASEAN Member State certified by the Tourism Professional Certification Board; and

2.14 **Tourism Professional Certification Board (TPCB)** refers to the government board and/or agency authorised by the government of each ASEAN Member State primarily responsible for the assessment and certification of Tourism Professionals.

## ARTICLE III
## RECOGNITION AND ELIGIBILITY OF FOREIGN TOURISM PROFESSIONALS

The qualification of a Foreign Tourism Professional may be recognised by other ASEAN Member States, and if such qualification is recognised, he/she may be eligible to work in a host country provided that he/she possesses a valid tourism competency certificate in a specific tourism job title as specified in the ACCSTP, issued by the TPCB in an ASEAN Member State. The eligibility to work in a host country will be subjected to prevailing domestic laws and regulations of the host country.

## ARTICLE IV
## BASIS OF RECOGNITION AND QUALIFICATIONS

4.1 The ASEAN Member States recognise that competencies based on qualification, education, training and/or experiences shall be the principal elements considered in granting mutual recognition of Foreign Tourism Professional; and

4.2 The ASEAN Member States are encouraged to apply the ACCSTP and CATC.

## ARTICLE V
## RESPONSIBILITIES

5.1 **National Tourism Professional Board (NTPB)**

The NTPB of each ASEAN Member State shall have the following responsibilities:

5.1.1 Create awareness and disseminate information about this Arrangement;

5.1.2 Promote, update, maintain, and monitor the ACCSTP and the CATC;

5.1.3 Facilitate the exchange of information concerning assessment procedures, criteria, systems, manuals and publications relating to this Arrangement;

5.1.4 Report its work progress to the ASEAN NTOs, including actions taken on cases referred to it by the TPCB and/or ATPMC;

5.1.5 Formulate and update necessary mechanisms to enable implementation of this Arrangement ;

5.1.6 Facilitate the exchange of best practices and prevailing developments in tourism sector with the view to harmonizing and updating regional and/or international tourism competencies and curricula; and

5.1.7 Such other functions and responsibilities that may be assigned to it by the ASEAN NTOs in the future.

## 5.2 The Tourism Professional Certification Board (TPCB)

The TPCB of each ASEAN Member State shall have the following responsibilities:

5.2.1 Assess qualifications and/or competencies of Tourism Professionals as specified in ACCSTP;

5.2.2 Issue certificates to Tourism Professionals whose qualifications and/or competencies have met the standards specified in ACCSTP;

5.2.3 Develop, process and maintain a registry of certified Tourism Professionals and job opportunities on the ATPRS; and

5.2.4 Notify the NTPB promptly in the event that foreign Tourism Professionals are no longer qualified to provide a particular service or have violated technical, professional or ethical standards;

## 5.3 ASEAN Tourism Professional Monitoring Committee (ATPMC)

The ATPMC shall have the following responsibilities:

5.3.1 Create awareness and disseminate information about this Arrangement on Tourism Professionals within ASEAN;

5.3.2 Promote, update, maintain and monitor the ACCSTP and the CATC;

5.3.3 Notify promptly the concerned TPCB upon receipt of feedback from NTPBs, in case a foreign Tourism Professional is no longer recognised by the host country;

5.3.4 Facilitate the exchange of information concerning assessment procedures, criteria, systems, manuals and publications relating to this Arrangement;

5.3.5 Report its work progress to the ASEAN NTOs;

5.3.6 Formulate and update necessary mechanisms to enable the implementation of this Arrangement; and

5.3.7 Such other functions and responsibilities that may be assigned to it by the ASEAN NTOs in the future.

## ARTICLE VI
## RIGHT TO REGULATE

This Arrangement shall not reduce, eliminate or modify the rights, powers and authority of each ASEAN Member State. ASEAN Member States, however, shall undertake to exercise their regulatory powers responsibly and in good faith without creating any unnecessary barriers towards each other.

## ARTICLE VII
## DISPUTE SETTLEMENT

7.1 ASEAN Member States shall at all times endeavour to agree on the interpretation and application of this Arrangement and shall make every attempt through communication, dialogue, consultation and cooperation to arrive at a mutually satisfactory resolution of any matter that might affect the implementation of this Arrangement.

7.2 The provision of the ASEAN Protocol on Enhanced Dispute Settlement Mechanism, done at Vientiane, Lao

PDR on 29 November 2004, shall apply to disputes concerning the interpretation, implementation, and/or application of any of the provisions under this Arrangement.

## ARTICLE VIII
## AMENDMENT

8.1 The provisions of this Arrangement may only be modified through amendments mutually agreed upon in writing by all ASEAN Member States.

8.2 Any revision, modification or amendments agreed to by the ASEAN Member States shall be reduced into writing and shall form part of this Arrangement.

8.3 Notwithstanding Article 8.1 above, the APPENDIX may be amended administratively by the ASEAN Secretary General upon notification by ATPMC.

8.4 Such revision, modification or amendment shall come into force on such date as may be determined by the ASEAN Member States.

8.5 Any revision, modification, or amendment shall not prejudice the rights and obligations arising from or based on this Arrangement prior or up to the date of such revision, modification, or amendment.

## ARTICLE IX
## FINAL PROVISIONS

9.1 Subject to Article 9.2, this Arrangement shall enter into force after all ASEAN Member States have completed and established the TPCB and NTPB or their equivalent bodies and notified the Secretary-General of ASEAN within one hundred and eighty (180) days from the date of its signing.

9.2 In the event that any ASEAN Member State has not completed and established the TPCB and NTPB or their equivalent bodies within one hundred and eighty (180) days from the date of signing, this Arrangement shall enter into force for that ASEAN Member State upon the date of notification in writing to the Secretary General of ASEAN of the completion and establishment of the TPCB and NTPB or their equivalent bodies.

9.3 This Arrangement shall be deposited with the Secretary-General of ASEAN, who shall promptly furnish a certified copy thereof to each ASEAN Member State.

9.4 This Arrangement or any part thereof shall only be terminated upon mutual agreement of the ASEAN Tourism Ministers upon recommendation of the ASEAN NTOs.

**IN WITNESS WHEREOF**, the undersigned, being duly authorized by their respective governments, have signed the ASEAN Mutual Recognition Arrangement on Tourism Professionals.

**DONE** at Bangkok, Thailand, this Ninth day of November in the Year Two Thousand and Twelve, in a single copy in the English Language.

For Brunei Darussalam:

**PEHIN DATO YAHYA**
Minister of Industry and Primary Resources

For the Kingdom of Cambodia:

**DR. THONG KHON**
Minister of Tourism

For the Republic of Indonesia:

**JERO WACIK**
Minister of Culture and Tourism

For Lao People's Democratic Republic:

**SOMPHONG MONGKHONVILAY**
Minister, Chairman of Lao National Tourism Administration

For Malaysia:

**DATO' SRI AZALINA DATO' OTHMAN SAID**
Minister of Tourism

For Union of Myanmar:

**BRIG GENERAL AYE MYINT KYU**
Deputy Minister, Ministry of Hotels and Tourism

For the Republic of the Philippines:

**JOSEPH H. DURANO**
Secretary, Department of Tourism

For the Republic of Singapore:

**S. ISWARAN**
Senior Minister of State for Trade and Industry

For Kingdom of Thailand:

**CHUMPOL SILAPA-ARCHA**
Minister of Tourism and Sports

For the Socialist Republic of Viet Nam:

**HOANG TUAN ANH**
Minister of Culture, Sports and Tourism

# ឧបសម្ព័ន្ធទី៥

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងទេសចរណ៍

លេខ ២១៦ ប្រក

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ [illegible] ឆ្នាំ២០១៤

## ប្រកាស
## ស្តីពី
## ការប្រើប្រាស់សៀវភៅជំនាញទេសចរណ៍

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍
## និងជាប្រធានគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០០ ស្តីពីការកែសម្រួលមុខងារនិងភារកិច្ច និងការបង្កើតក្រុមអ្នកច្បាប់ និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងអាស៊ាននៃក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៣៤ សសរ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការតែងតាំងសមាសភាពរបស់គណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍
- យោងតាមស្មារតីនៃកិច្ចប្រជុំគណៈកម្មការជាតិអ្នកជំនាញទេសចរណ៍ នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៤ និងយោងតាមតម្រូវការចាំបាច់នៃការងាររបស់គណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍

## សម្រេច

**ប្រការ ១.**

ប្រកាសនេះមានគោលបំណងដាក់ឱ្យប្រើប្រាស់សៀវភៅជំនាញទេសចរណ៍ ដូចមានក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ ដើម្បីលើកកម្ពស់ និងអភិវឌ្ឍជំនាញទេសចរណ៍ ប្រកបដោយប្រសិទ្ធិភាព និងគុណភាពខ្ពស់។

Scanned by CamScanner

សៀវភៅជំនាញទេសចរណ៍ គឺជាសក្ខីបណ្ណដែលបញ្ជាក់អំពីសមាសធាតុនៃគុណវុឌ្ឍិរបស់អ្នកជំនាញទេសចរណ៍។

**ប្រការ ២._**

សៀវភៅជំនាញទេសចរណ៍ត្រូវបានដាក់ឱ្យប្រើប្រាស់ដល់អ្នកជំនាញទេសចរណ៍ និយោជកនៃវិស័យទេសចរណ៍ អង្គភាព ឬកម្មវិធីបណ្តុះបណ្តាលជំនាញទេសចរណ៍។

កំណត់ត្រាក្នុងសៀវភៅជំនាញទេសចរណ៍ អាចយកទៅប្រើប្រាស់ជាភស្តុតាងនៃការវាយតម្លៃសមត្ថភាព ការជ្រើសរើសបុគ្គលិក ការផ្តល់រង្វាន់ ឬការធ្វើផែនការអភិវឌ្ឍជំនាញ។

**ប្រការ ៣._**

សៀវភៅជំនាញទេសចរណ៍នេះ ប្រើប្រាស់សម្រាប់កត់ត្រាគុណសម្បត្តិចំនួនបីសំខាន់ៗ របស់អ្នកជំនាញទេសចរណ៍ដូចជាៈ

(១) **ការចូលរួមវគ្គបណ្តុះបណ្តាល**

វគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈរយៈពេលខ្លី មធ្យម និងវែង ទាំងក្នុង និងក្រៅប្រទេសស្តីពីជំនាញជាក់លាក់ណាមួយ កម្មសិក្សា ព្រមទាំងវគ្គបណ្តុះបណ្តាលដែលរៀបចំដោយផ្ទាល់នៅក្នុងស្ថាប័ន។

(២) **លិខិតសរសើរ ឬពានរង្វាន់ផ្សេងៗ**

អ្នកជំនាញទេសចរណ៍ ឬស្ថាប័នអាចស្នើសុំឲ្យមានការកត់ត្រាអំពី លិខិតសរសើរ ស្នាដៃ ឬពានរង្វាន់ផ្សេងៗដែលខ្លួនទទួលបាន។ លិខិតសរសើរ ស្នាដៃ ឬពានរង្វាន់គឺជាផ្នែកមួយនៃសក្ខីបណ្ណ ដែលបញ្ជាក់អំពីសមត្ថភាពអ្នកជំនាញ ហើយដែលនឹងអាចត្រូវបានប្រើប្រាស់សម្រាប់ធ្វើការវាយតម្លៃសមត្ថភាពផងដែរ។

(៣) **បទពិសោធន៍ការងារ**

បទពិសោធន៍ការងារ ដែលអ្នកជំនាញទេសចរណ៍បានទទួលនៅក្នុងអាជីពការងាររបស់ខ្លួនអាចស្នើសុំការបញ្ជាក់ ឬកត់ត្រាក្នុងសៀវភៅជំនាញទេសចរណ៍។

**ប្រការ ៤._**

ដើម្បីទទួលបានការកត់ត្រារាល់គុណសម្បត្តិដូចមានចែងក្នុង ប្រការ ៣ សាមីខ្លួន ឬអង្គភាពរបស់ខ្លួនត្រូវធ្វើការស្នើសុំតាមរយៈលិខិតទៅប្រធានគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍ (គ.ជ.អ.ទ.) ដោយភ្ជាប់នូវឯកសារយោង ឬសក្ខីបណ្ណផ្សេងៗ។

បន្ទាប់ពីបានទទួលការឯកភាពពីប្រធាន គ.ជ.អ.ទ. លេខាធិការដ្ឋានអាចចុះកត់ត្រារាល់គុណសម្បត្តិដែលទទួលបានការឯកភាព ក្នុងសៀវភៅជំនាញទេសចរណ៍ ដោយមានចុះហត្ថលេខាទទួលស្គាល់ដោយប្រធានលេខាធិការដ្ឋាន គ.ជ.អ.ទ. ។

លេខាធិការដ្ឋាន គ.ជ.អ.ទ. អាចបញ្ចូលរាល់ទិន្នន័យអំពីការកត់ត្រាទាំងនេះក្នុងប្រព័ន្ធព័ត៌មានវិទ្យារបស់ខ្លួន។



Scanned by CamScanner

**ប្រការ ៥._**

រាល់ទិន្នន័យ ដែលបានកត់ត្រានៅក្នុងសៀវភៅជំនាញទេសចរណ៍នេះមានសុពលភាព ដរាបណាមានការទទួលស្គាល់ពី គណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍។

**ប្រការ ៦._**

គណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍ប្រើប្រាស់សៀវភៅនេះដើម្បីជាសក្ខីបណ្ណបញ្ជាក់សមត្ថភាពក្នុងដំណើរការវាយតម្លៃអ្នកជំនាញទេសចរណ៍អាស៊ាន។

**ប្រការ ៧._**

អ្នកជំនាញទេសចរណ៍ និយោជក អង្គភាព ឬកម្មវិធីអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍នៅព្រះរាជាណាចក្រកម្ពុជា ត្រូវប្រើប្រាស់សៀវភៅជំនាញទេសចរណ៍ ដើម្បីចូលរួមលើកកម្ពស់ និងអភិវឌ្ឍជំនាញទេសចរណ៍ ព្រមទាំងផ្តល់ជាភស្តុតាងសម្រាប់ធ្វើការវាយតម្លៃអ្នកជំនាញទេសចរណ៍កម្ពុជា និងអាស៊ាន។

**ប្រការ ៨._**

សៀវភៅជំនាញទេសចរណ៍ អាចនឹងត្រូវបានធ្វើបច្ចុប្បន្នភាពតាមតម្រូវការចាំបាច់។

**ប្រការ ៩._**

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ១០._**

សមាជិក គ.ជ.អ.ទ. រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយកទេសចរណ៍ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុនៃក្រសួងទេសចរណ៍ គ្រប់ប្រធាននាយកដ្ឋាន ប្រធានក្រុមអ្នកច្បាប់នៃក្រសួងទេសចរណ៍ លេខាធិការដ្ឋាន គ.ជ.អ.ទ. ប្រធានមន្ទីរទេសចរណ៍រាជធានី-ខេត្ត និងអង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**គណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍**

**ប្រធាន**

**ថោង ខុន**

**រដ្ឋមន្ត្រីក្រសួងទេសចរណ៍**

*កន្លែងទទួល៖*

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ១០
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



Scanned by CamScanner

កម្ពុជា

ព្រះរាជាណាចក្រអច្ឆរិយៈ

ផ្តល់ភាពកក់ក្តៅ